ROYAUME DU CAMBODGE
REGIE DU DEPOT LEGAL

ទ.គោចន

# ៤០ សរសេរតាមសូត្រ

## សម្រាប់គ្រប់ថ្នាក់



# 40 DICTÉES KHMÈRES

## POUR TOUTES LES CLASSES

៤០ សរសេរតាមសូត្រ

សម្រាប់គ្រប់ថ្នាក់

ដោយ

# វ.វតាខន

ការផ្សាយរបស់




លេខ ១៩-២១ វិថីព្រះបទុមផា

ក្រុងភ្នំពេញ

បោះពុម្ពផ្សាយលើកដំបូងចំនួន ១.២០០ ច្បាប់

ព.ស. ២៤៩៩ គ.ស. ១៩៥៦

រក្សាសិទ្ធិគ្រប់យ៉ាង

B-248

# ពាក្យអ្នករៀបរៀង

គ្មានអ្វីក្រៅពីចង់ឲ្យក្បួនច្បាប់ជាអក្សរសាស្ត្រជាតិមាន កើតឡើងច្រើនឡើង ៗ យើងខ្ញុំរៀបរៀងសៀវភៅ « ៤០ សរសេរតាមសូត្រ » នេះឡើង ក៏ព្រោះតែចង់ឲ្យបានទុកជា មិត្តរបស់លោកគ្រូ-អ្នកគ្រូនិងសិស្សានុសិស្សតែប៉ុណ្ណោះ ។

ដូចនេះ គ្មានវាចាអ្វីនឹងឲ្យពីរោះ គ្រាន់ទុកជាគ្រឿង ពិគ្រោះ ដល់លោកគ្រូ-អ្នកគ្រូនិងសិស្សានុសិស្សទេ ។

ប៉ុន្តែ យើងមានសេចក្តីសង្ឃឹមកក់ក្តៅយ៉ាងមាំថាលោក គ្រូ-អ្នកគ្រូនិងសិស្សានុសិស្សមុខជាខំជួយខ្នះខ្នែងពង្រីកអក្សរ-សាស្ត្រជាតិរឹតតែឲ្យបានចំរើនខ្លាំងឡើង ៗ ជាមិនខាន ។

សួស្តីអក្សរសាស្ត្រសម័យឯករាជ្យ

រ. គោវិធ

# អក្សរសំខេប

## សម្រាប់ប្រើក្នុងសៀវភៅនេះ

| ពាក្យបំប្រួញ | ត្រូវអានថា | ប្រែថា |
|---|---|---|
| កិ. | កិរិយាសព្ទ | verbe |
| កិ. នុ. | កិរិយានុគ្រោះ | verbe auxiliaire |
| កិ. វិ. | កិរិយាវិសេសន៍ | adverbe |
| គុ. | គុណសព្ទ | adjectif |
| ន. | នាមសព្ទ | nom |
| នបុំ. | នបុំសកលិង្គ | genre neutre |
| ន. ប្រ. | ន័យប្រៀប | sens figuré |
| និ. | និបាតសព្ទ | mot euphonique |
| ប. សំ. | បកតិសំខ្យា | adjectif numéral |
| បុ. ស. | បុរិសសព្ទនាម | pronom personnel |
| បុំ. | បុំលិង្គ | masculin |

| | | |
|---|---|---|
| បូ. សំ | បូរណសំខ្យា | adjectif numéral ordinal |
| ពហុ. | ពហុវចនៈ | pluriel |
| ម. | ភាសាមគធៈ | langue (magatha) |
| ម. សំ. | មគធៈនិងសំស្រ្កឹត | magatha avec sanscrit |
| រ. ស. | រាជស័ព្ទ | terme royal |
| វិ. ស. | វិសេសនសព្វនាម | espèce du pronom démonstratif |
| វេវ. | វេវចនៈ | synonyme |
| សន្ធ. | សន្ធាន | conjonction |
| សព្វ. | សព្វនាម | pronom |
| សំ. | ភាសាសំស្រ្កឹត | langue (sanscrit) |
| សំខ្យា. | សំខ្យាស័ព្ទ | adjectif numéral |
| អា. និ. | អាយតនិបាត | mot enphonique de temps |

| | | |
|---|---|---|
| ស. | ស្ត្រីលិង្គ | féminin |
| ឧ. | ឧទានស័ព្ទ | interjection |
| ឯក. | ឯកវចនៈ | singulier |

## ១. វិជ្ជាជាគ្រឿងបើកផ្លូវ

ជីវិតនៃមនុស្សយើងនេះ មានវិជ្ជាជាគ្រឿងបើកផ្លូវឲ្យដើរទៅរកឋានៈដ៏ឧត្ដុង្គឧត្ដមបាន ។ ពូជពង្សជាន់វណ្ណៈឬជាតិត្រកូល ដែលគេធ្លាប់តែនាំគ្នាប្រកាន់នោះ មិនមែនជាកូនសោសម្រាប់បើកផ្លូវឲ្យជីវិតនៃមនុស្ស ធ្វើដំណើរទៅកាន់សេរី-វឌ្ឍនភាពបានឡើយ ។ សុភមង្គលក្នុងជីវិតនៃមនុស្សយើងគ្រប់រូប ដែលនឹងបានសម្រេចនោះ ក៏ដោយសារតែវិជ្ជាដែលយើងខំប្រឹងតស៊ូយកជ័យជំនះក្នុងធម្មជាតិ ។ ដូច្នេះ ជីវិតនៃមនុស្សយើងបើគ្មានវិជ្ជា ក៏មិនខុសគ្នាពីសម្លដែលគ្មានរសជាតិនៃអំបិលដែរ ។ បើគ្មានវិជ្ជាប្រចាំនៅក្នុងខ្លួនហើយ មុខជាគ្មានពេលនឹងសង្ឃឹមនូវឋានៈនៃជីវភាព ដ៏ខ្ពង់ខ្ពស់ថ្កុំថ្កើងបានឡើយ ។ បើទុកជាអ្នកនោះមានថ្នាក់ជាន់វណ្ណៈឬឋានន្ត-ស័ក្តិឬជាតិត្រកូលខ្ពស់យ៉ាងបំផុតក៏ដោយ បើគ្មានវិជ្ជាក៏គ្មានពន្លឺដែរ ។ តែជាការផ្ទុយទៅវិញ, បើទុកជាអ្នកនោះកើត

ឡើងក្នុងជាន់វណ្ណៈ ឬជាតិត្រកូលដ៏ខ្សត់ខ្សោយ ឬទន់ទាបយ៉ាងណាក៏ដោយ, បើមានវិជ្ជាប្រចាំនៅក្នុងខ្លួនហើយ, អ្នកនោះអាចកែប្រែជីវិតខ្លួនពីសភាពខ្សត់ខ្សោយ ឬទន់ទាបនោះ ឲ្យឡើងទៅកាន់ឋានៈដ៏ខ្ពង់ខ្ពស់បាន ។

គ. ពាក្យពន្យល់

ជីវិត = ន. ដំណើររស់នៅ, អាយុ (vie) ។

វិជ្ជា = ន. សេចក្ដីដឹងច្បាស់, ការចេះដឹង, បំណេះ ។

ឧត្តុង្គឧត្តម = (ម.ថ. អ៊ុត-ដុង-អ៊ុត-ដំ) គុ. ខ្ពង់ខ្ពស់លើសលែង, ប្រសើរកន្លង ។

វណ្ណៈ = ន. (ទីនេះ) ភេទ, ពូជពង្ស, ថ្នាក់នៃមនុស្ស ។

សេរីវឌ្ឍនភាព = ន. ដំណើរនាំឲ្យចំរើនដោយសេរី ។

សុភមង្គល = (ម.ថ. សុ-ភៈ-ម័ង-គល់) ន. មង្គលល្អ គ្រោះល្អ

រសជាតិ = (ម.ថ. រស់-ជាត) ន. ជាតរបស់រស, រស

ធ្ងាញ់ពិសា ។

ហេតុៈ=(ម.ថ.ហា-ត៉ៈ)ន. ហេតុ, ដំណើរ,ទីតាំង, ថ្នាក់, លំដាប់ ។

ជីវភាព=(ម.ថ.ជី-វៈភាប) ន. ដំណើររស់នៅ, ភាពនៃការរស់នៅ ។

ហិរញ្ញសក្តិ, -សក្តិ=(ម.ថ. ហាន់ន៉ត៉ៈ-ស័ក) ន. អំណាចតាមមុខងារ, បណ្ដាស័ក្តិធំតូចតាមមុខងារ ។

១. អត្ថាភិធាន

## កប់ – គាប់

កប់=កិ. បង្កប់ឲ្យលិចបាត់មើលមិនឃើញ, ឧទា. កប់ខ្មោច, កប់ប្រាក់លាក់ទុក, កប់ដើមបេកចៅក្នុងដី ។

កប់=គុ. ដែលលិចបាត់ទៅ , ឧទា. ប្រាក់នេះជាប្រាក់កប់ ឥតមានចំណេញអ្វីទេ ។ ទ្រព្យកប់ . . .

គាប់=គុ. ត្រូវ, ឥតខុស, ឥតទាស់, ឧទា. ទ្រព្យនេះជាទ្រព្យគាប់ប្រសើរ ។ កេរ្តិ៍នេះបានជាទីគាប់ចិត្តនៃជនទាំងពួង ។

## ឧដុង្គ ឬ ឧត្តុង្គ

ពាក្យនេះអាចសរសេរបានដូចគ្នា តែគួរសរសេរ ជា ឧត្តុង្គ នេះវិញ ។

សង្កេត ឧត្តុង្គ សរសេរជា: ឧ + ត + ្ត (ជើងត) + ុ, + ង + ្គ (ជើងគ), អានថា អុត-ដុង ។

## ពង់ - ពង្ស

ពង់=កិ. បំកោង, បំអត, ឧទា. ក្អាកពង់ ដើម្បីបង្អួតពង ។

ពង់=កិ. ដោរខ្ទាតឡើង, ឧទា. ស្រោមដៃនាងតូចស្រាប់តែពង់ខ្ទុះតែម្តង ។

ពង់ = គុ. (ន. ប្រ.) ក្រអឺតក្រអោន, ប៉ឺតប៉ោន ដោយដំឡើងបុក, ឧទា. ក្អេងនេះបុកពង់ ។

ពង្ស = (ថ. ម. ពង់) ន. វង្ស, ត្រកូល, ពូជ, ឧទា. ពូជពង្សវង្សត្រកូលរបស់គេខ្ពង់ខ្ពស់ណាស់ ។

## ២.ការរៀនសូត្រ

មនុស្សចាប់ផ្តើមរៀនសូត្រតាំងពីថ្ងៃកើតមក ដូចយើងបានឃើញទារក ដែលចេះសម្លឹងមើលមុខម្តាយរបស់ខ្លួនដើម្បីរៀនមើលលក្ខណៈ មុខមាត់ម្តាយដែលជាអ្នកបីបាច់ព្យាបាលឲ្យទឹកដោះខ្លួនទៅជាដើម ៗ មួយវិញទៀត ប្រសិនបើយើងពិនិត្យមើលក្នុងខ្លួនមនុស្ស ក៏គង់ឃើញច្បាស់ថាមនុស្សយើងមានចិត្តជាគ្រឿងដឹង មានប្រសាទទាំងប្រាំជាគ្រឿងប្រាប់ ៗ ប្រសាទប្រាប់មកយ៉ាងណា ចិត្តក៏ដឹងយ៉ាងនោះដែរ ប្រសិនបើចិត្តចង់ការត្រូវដឹងឲ្យច្រើនជាងនេះ ក៏ប្រើប្រសាទពិនិត្យត្រួតត្រាទៅទៀតឬយកចំណេះ ដែលបានមកតាមផ្លូវប្រសាទ មកញែកវែកមើលឲ្យជាក់លាក់តទៅទៀត ដែលជាផ្លូវរកចំណេះបានមួយផ្លូវទៀតដែរ ។

ផលនៃការសិក្សា គឺសេចក្តីចេះដឹង ឯចំណេះចេះដឹងរបស់មនុស្សយើង ជាវិស័យរបស់មនុស្សដែលមាននៅតាម

ប្រក្រតីធម្មតា តែការចង់ចេះដឹងនេះមានមិនស្មើគ្នា គឺអ្នកខ្លះចង់ចេះដឹងមានកំឡាំងទន់ខ្សោយ អ្នកខ្លះមានការចង់ចេះដឹងយ៉ាងខ្លាំងក្លា ៗ ពោលចំពោះមនុស្សដែលចង់ចេះដឹងយ៉ាងខ្លាំងប៉ុណ្ណោះដែលបានឈ្មោះថា ជាអ្នកសិក្សាមែនៗ ពួកអ្នកសិក្សានេះឯងជាអ្នកធ្វើគុណប្រយោជន៍ យ៉ាងធំក្រៃលែងដល់ប្រទេស ។

ទស្សនាវដ្ដីសម្រាប់គ្រូបង្រៀន

ក. ពាក្យពន្យល់

ទារក=(ម.ថ.ទា-រក់)ន. ក្មេងប្រុសតូច, កូនខ្ចី ។

លក្ខណៈ=(ម.ថ ល័ក-ខៈណៈ) ន. គ្រឿងសំគាល់, គ្រឿងសង្កេតនាខ្លួនប្រាណ, គុណសម្បត្តិ ។

ប្រសាទ=(ម.ថ.–សាត)ន. អាយតនៈសម្រាប់ទទួលសម្ផស្ស និងអារម្មណ៍ ។

វិស័យ=(ម.ថ.-វៃស)ន. គំនិត, អារម្មណ៍ ។

ប្រក្រតី=(ម.ថ.ប្រក់ក្រ-ដី)ន. ធម្មតា, ការប្រព្រឹត្តិទៅតាម បំណាំ, ដំណើរតាំងនៅដូចដែល ។

គុណប្រយោជន៍=(ម. ថ. គុណៈប្រយោ៉ច)ន. សេចក្ដីល្អ និងប្រយោជន៍ ។

## ១. អក្ខរាវិរុទ្ធ

## កល-កល់-គាល់

កល = (ម. ថ. កល់) ន. ឧបាយយ៉ាងល្អិត, ល្បិច (ឧបាយកល), ឧទ. ដំណើរហ្នឹងជាកលឧបាយរបស់គេទេ ។ នែកូន! ប្រយ័ត្នបាញ់កលគេហ្ន៎ះ!

កល់ = កិ. ទ្រពីក្រោម, សែមពីក្រោមដើម្បីឲ្យស្មើមិនឲ្យល្អៀង ឬដើម្បីឲ្យហើបឲ្យខ្ពស់ឡើង, ឧទ. គេយកកំណល់មកកល់ទូកដើម្បីឲ្យហើប ។

គាល់= កិ. អង្គុយក្តុងសំណាក់ស្តេច, ទៅកាន់សំណាក់ស្តេច, ឧទា. ទុកញ៉ាំមហាមន្ត្រីបានអញ្ជើញទៅគាល់ ព្រះមហាក្សត្រនៅព្រះទីនាំងភោជនីយ ។

## កល្ប-កាល់

កល្ប=(ម.ថ.កាល់) ន.កាលដែលតាំងនៅយូរអង្វែង, ឧទា. គ្មានមនុស្សណាសូម្បីមួយនាក់ ដែលអាចរស់នៅអស់កប្បអស់កល្បបានឡើយ ។

កាល់= កិ. ពានគ្នា, (ពាក្យសំរាប់និយាយចំពោះសត្វចង់គ្នា), ឧទា.គោកាល់ញី ។

កាល់= កិ. ដំរីម, ឧទា. ដាំងកាត់សក់ កំពុងកាល់ជើងសក់ជូនលោក ។

កាល់= កិ. ខាខាំងមិនឲ្យប្រទូកប្រទាំលាយគ្នា ឧទា. គោកាល់ហ្វូង ។

## ៣. សម័យអក្សរសាស្ត្រ

អក្សរតែងប្រែប្រួលសភាពលក្ខណៈ ថ្មែក ៗ គ្នាពីសម័យមួយទៅសម័យមួយ ហើយសម័យនោះ ៗ ជាវត្ថុជាស្រ-មោលនៃការវិវត្តន៍ប្រវត្តិរបស់ប្រទេសក្នុងជំនាន់នោះ ៗ អ្នកសិក្សាគប្បីចេះវែកកត់សំគាល់នូវលក្ខណៈសំខាន់ ៗ នៃសម័យនោះ ឬសតវត្សរ៍នោះឲ្យឃើញប្រាកដ ៗ ឧទាហរណ៍ដូចសម័យអង្គរ ជាសម័យដែលគេជានុភាពព្រះមហាក្សត្រផ្កាយរស្មីរុងរឿងជាទីបំផុត ដែលមានរបៀបរៀបរយ និងមានវិន័យបរិបូណ៌ ៗ ចលនានៃអក្សរសាស្ត្រក្នុងសម័យនោះ មាននាំគៃក្រាយលុងលុយទូលំទូលាយជាក់លាក់ហើយបញ្ចេញបញ្ចូលហួសហេតុជាពិតញាប់ផង ដែលសិលាចារឹកជំនាន់នោះបានសួនទុកពេញត្រៀបស្រាប់ ៗ ចំណែកសម័យក្រោយអង្គរ ជាសម័យច្របូកច្របល់វិយោគសោកស្តាយ ផុតសង្ឃឹមកិច្ចការជាស្នាដៃនៃជាន់នោះច្រើនតែរកចប់ពុំឃើញ ហើយវិល

រល់ដដែល ៗ ដោយការស្រេះស្រោចជាដើម ៗ ចំណែក ឯពាក្យពេចន៍ភាសាសំដីអក្ខរាវិរុទ្ធ នឹងវាក្យសម្ពន្ធ ក៏ផ្សេងៗគ្នា តាមលំដាប់សម័យនោះ ៗ ដែរ ។

## ក. ពាក្យពន្យល់

សម័យ=(ម.ថ. ស ម៉ៃ)ន. កាល, ពេលវេលា, ឱកាស, គ្រា

សភាព= (ម.ថ. សៈភាព) ន. ដំណើរកើតឯង, ធម្មតា, ការប្រព្រឹត្ត, សេចក្ដីពិតតាមធម្មតា ។

រស្មី=(ម.ថ.រ័ស-ស្មី) ន. ពន្លឺដែលមានខ្សែចាំងព្រាតៗ ។

អារ្យធម៌= (ម.ថ. អារ-យ៉ៈធ័រ) ន. ធម៌ដែលនាំឲ្យកើតសេចក្ដីសុខ-ចំរើន, សណ្ដាប់ឬបែបបទរៀបរយ ។

ពង្សាវតារ=(ម.ថ. ពង់-សា-វ៉ៈតារ) ន. រឿងរ៉ាវ តាមលំដាប់នៃវង្សត្រកូល, ដំណើរសេចក្ដីសំដែងអំពីដំណាលនៃវង្សត្រកូល ។

សតវត្សរ៍, -វត្ស= (ម.ថ. សៈតៈវ័ត) ន. ការកំណត់មួយរយឆ្នាំ ឬមួយខួបរយឆ្នាំ, ឆ្នាំមួយរយ ។

ប្រាកដ= (ម.ថ. ប្រប័ក) គុ.ឬកិ.វិ. ដែលជាក់, ច្បាស់, មែន ។

ឧទាហរណ៍= (ម.ថ. អ៊ុ-ទា-ហ) ន. ការលើកឡើងឲ្យឃើញ, គំរូ, គ្រឿងសំអាង, ការនាំមកពន្យល់ ឬបង្ហាញឲ្យឃើញ ។

តេជានុភាព= (ម.ថ. តេជានុភាប) ន. អំណាចនឹងអានុភាព, អំណាចដ៏ខ្លាំង, កម្លាំងនៃអំណាច ។

វិន័យ= (ម.ថ.វិនៃ) ន. ការដឹកនាំទៅរកផ្លូវល្អ, ច្បាប់បញ្ញត្តិ ឬច្បាប់អនុញ្ញាត, ច្បាប់ប្រដៅឲ្យមានសណ្ដាប់ធ្នាប់ល្អ ។

បរិបូណ៌= (ម.ថ. បរ៉ិបូ ឬប-បូ) គុ. ដែលគ្រប់គ្រាន់ពេញលេញ, សម្បូណ៌ ។

បលនា = (ម. ថ. ប: ល: នា) ន. ការកំរើករំពើក (mouvement) ។

អក្សរសាស្ត្រ = (ម. ថ. អ័ក-ស-សាស) ន.ក្បួនច្បាប់វិធីអក្សរ, វិជ្ជាអក្សរ ។

កែក្រាយ = គុ. ដែលមានដំណើរដូចល្មោនកាំ ។

លង្គលា្គយ = គុ. ឬ កិ. វិ. ដែលមានលំនាំដំណើរគាយទន់ភ្លន់ញើរផ្ញើរឥតគាត ។

បញ្ចើបញ្ចោល = កិ. ពោលពាក្យលើកសរសើរហួសហេតុហួសទំនង ។

សិលាចារឹក = (ម. ថ. សិលា–) ន. អក្សរថ្ម ។

ស្ងួនទុក = កិ. រក្សាទុក, ថែទាំទុក ។

វិយោគ = (ម. ថ. វិយោក) ន. ការព្រាត់ប្រាស (ចាកបុគ្គល ឬ អ្វី ៗ ដែលស្រឡាញ់ពេញចិត្ត) ។

អក្ខរាវិរុទ្ធ = (ម. ថ. អ័ក - ខៈ រ៉ាវិរុត) ន. វិធីសម្រាប់សរសេរដោយត្រឹមត្រូវ (Orthographe) ។

វាក្យសម្ពន្ធ = (ម. ថ. វ៉ា - ក្យៈ - ស័ម - ព័ន) ន. ការចងភ្ជាប់នូវពាក្យ, ការប្រាប់ឲ្យដឹងថាពាក្យនេះជានាមឬជាគុណនាមជាដើម (analyse des mots) ។

១. អក្ខរាវិរុទ្ធ

## ប្រួល - ព្រួល

ប្រួល = ប. ពាក្យសម្រាប់និយាយផ្សំ នឹងពាក្យប្រែ ឧទា. គំនិតរបស់គាត់ចេះតែប្រែប្រួលជានិច្ច ។

ព្រួល = ន. កម្រងបន្ទោះធំៗឬរនាបតូចៗសម្រាប់ទស់ទាំងមច្ឆជាតិឬសម្រាប់អបស្អួបដៃជើងបាក់ជាដើម, ឧទា. អ្នកនេសាទវៃងព្រួលដើម្បីធ្វើលប ។ គ្រូពេទ្យយកព្រួលមកចងអបស្អួបដៃក្មេងដែលបាក់ ។

ព្រួប= ន. ឈ្មោះស្វាយមួយយ៉ាង, ឧទា ស្វាយម៉ីង ព្រួល ។

ព្រួល= ន. ឈ្មោះត្រីស្រកាពួកមួយ មានសម្បុរស ឧទា. ស្ងោរត្រីព្រួលឆ្ងាញ់ណាស់ ។

ព្រួលម្ភព្រួលៗ=កិ. វិ. ឬគុ. ទ្រួសៗ, លំៗ, ស្មើរៗ, ព្រាងៗ, ឧទា. ចាំព្រួលៗ; ឆ្អិនព្រួលៗ ។ ក្រហមព្រួលៗ; លឿង ព្រួលៗ ។

## ៤. ការសិក្សា

ការដែលយើងមានសេចក្ដីចេះដឹងស្ទាត់ជំនាញ លុះតែអាស្រ័យការសិក្សារៀនសូត្រជាមុនសិន ហើយឱកាសដែលយើងត្រូវរៀនសូត្រឲ្យចេះដឹងល្អ ក៏គឺពេលដែលខ្លួននៅក្មេង ព្រោះឱកាសនេះយើងមិនសូវកង្វល់នឹងរបរចិញ្ចឹមជីវិត មាតាបិតាឬអ្នកអភិបាលបញ្ជូនខ្លួនយើងឲ្យទៅរៀនសូត្រក្នុងសាលា ដើម្បីឲ្យយើងមានចំណេះវិជ្ជា ៗ កាលធំចំរើនឡើង នឹងនាំយកចំណេះអស់នោះធ្វើការចិញ្ចឹមជីវិតបានស្រួល តែចំណេះវិជ្ជាដែលយើងត្រូវរៀននោះ មានច្រើនយ៉ាងច្រើនប្រការ បើរួមឲ្យខ្លីទៅមានពីរប្រការ គឺសាមញ្ញវិជ្ជាបានខាងចំណេះដែលត្រូវចេះរាល់គ្នា ដូចវិជ្ជាអក្សរ, លេខ, ចរិយា, អនាម័យជាដើមៗ មួយទៀតគឺវិសាមញ្ញវិជ្ជា បានខាងចំណេះវិជ្ជាណាមួយដែលត្រូវរៀនឲ្យចេះស្ទាត់ដោយឡែក គឺវិជ្ជាអាជីវកម្ម ៗ យើងមុននឹងចេញពីសាលារៀន ត្រូវគិតរៀនវិជ្ជាអាជីវកម្មឲ្យសម្រេច

ជាមុនសិន សឹមចេញទៅធ្វើការរកទទួលទានតាមភូមិប្រទេស របស់ខ្លួនឬតាមវិជ្ជាការរបស់ខ្លួន ទើបសម្រេចបានដូចបំណង។ តាមធម្មតា មនុស្សយើងត្រឹមម្នាក់ៗ មិនអាចធ្វើការងារនានា បានគ្រប់យ៉ាងទេ គេតែងអាស្រ័យផ្លាស់ប្តូរគ្នាទៅវិញទៅមក។

ទស្សនាវដ្តីសម្រាប់គ្រូបង្រៀន

## ឃ. ពាក្យពន្យល់

អាស្រ័យ= កិ. ពឹងពាក់ពំនាក់, ប្រព្រឹត្តទៅបានដោយសារ,។

ឱកាស= ន. វេលា, ពេល, ទំនង ។

កង្វល់= កិ. រវល់, ខ្វល់, វឹកវរ ។

អ្នកអភិបាល= (ម.ថ.នាក់-អៈភិបាល) ន. អ្នកគ្រប់គ្រង ថែរក្សា ។

សាមញ្ញវិជ្ជា= (ម.ថ.សាម៉ុញ-ញៈ-) ន. វិជ្ជាធម្មតា ។

បរិយា= (ម.ថ.ប៉ៈរ៉ុយ៉ា) ន. បែបបទមារយាទ, ការប្រព្រឹត្ត

អនាម័យ= (ម.ថ.អៈនាម៉ៃ) ន. ដំណើរមិនមានរោគ, សេចក្ដីសុខសប្បាយខ្លួន (hygiène) ។

វិសាមញ្ញវិជ្ជា= (ម.ថ. វិសា-ម៉ុញ-វិជ្ជា) ន. វិជ្ជាដែលប្លែកពីធម្មតា ។

វិជ្ជាអាជីវកម្ម= ន. វិជ្ជាខាងការរកស៊ីចិញ្ចឹមជីវិត ។

១. អក្ខរាវិរុទ្ធ

ពី–ពីរ

ពី= និ., គា. និ. អំពី, ខាង, ឯ, ឧទា. អ្នកទើបអញ្ជើញមកពីណា ?

ពីរ= ប.សំ. ចំនួនគូបគា គឺមួយនឹងមួយ, ឧទា. យើងមកតែពីរនាក់គត់ ។

សង្កេត.– ពាក្យដែលមានព្យាង្គពីរឬព្យាង្គច្រើន,ហើយពាក្យនោះផាប់ដោយ ពី ពីខាងមុខ, គេច្រើនបរសេរនឹងពី (ពុំ

សូវសរសេរនឹងពិឡើយ) ឧទា. ពីព្រោះ, ពីរេះ, ពីសាឬពិ-សា, ពីសី ឬពិសី ។ល។

វៀរលែងតែពាក្យនោះជាពាក្យបាលី ឬសំស្ក្រឹត ទើបគេសរសេរនឹងពិ (គឺពិទាំងអស់)

ឧទា. ពិសេស, ពិសាល, ពិសោធ, ពិរុណ, ពិភេធ, ពិលាប, ពិភាក្សា, ពិមាន,...

# ៥. អំពីភ្នំ

ប្រទេសកម្ពុជា ជាប្រទេសសំបូណ៌ដោយភ្នំណាស់ ៗ នៅទិសឧត្តរមានភ្នំធំៗហើយវែងៗពាសពាស់ព្រំដែនខ្មែរ - ថៃ មាននាមថា សហគិរីដងរែក ៗ នៅទិសនិរតី មានសហគិរីមួយ ឈ្មោះភ្នំក្រវាញ មួយទៀតហៅភ្នំកំចាយ ឬភ្នំដំរី ៗ នៅកណ្ដាលប្រទេសនឹងនៅភូមិភាគឯទៀតៗ គេឃើញមានភ្នំតូចៗ ជួនកាលមានក្បាលតាជាតិ ដុះទ្រុបទ្រុលពាសពេញ ជួនស្ថិតនៅកណ្ដាលស្រុកដាច់តែឯង ៗ ប្រស្រ័យដោយសម្បូរណភាពនៃភ្នំទាំងឡាយយ៉ាងនេះហើយ បានជាក្នុងបឋមសម័យប្រទេសកម្ពុជាមាននាមថា « ពជធានីសម័យនគរភ្នំ ៗ

គន់មើលអំពីចម្ងាយ មហាគិរីដ៏មានសណ្ឋានខ្ពាល្ហប់ ហាក់ដូចជាផុសផុះចេញពីផែនដី សំដៅឡើងអាកាសវេហាស៍ៗ កាលណាគេបានទៅជិតបន្តិចម្ដងៗ គេឃើញមហាគិរីសើដែន ឫទ្ធិអានុភាពកាន់តែធំហើយខ្ពស់ត្រដែត ៗ ភ្នំទាំងឡាយ

បំរើនូវផលគានដល់ប្រទេស ជាថ្មសម្រាប់ក្រាលថ្នល់ សង់គេហដ្ឋាន, ជាឈើរឹងសម្រាប់ធ្វើតុទូ, ជាឈើសង់ផ្ទះ, ជាឈើសម្រាប់អុសដុត, ជាថ្នាំសង្កូវ ជាវល្លិ៍ឫស្សីទឹកជ័រ ។ល។ នៅក្នុងក្រវាញគេបេះផ្លែក្រវាញធ្វើឱសថដ៏ប្រសើរ ។

ឈិម - សុំផន

## ៣. ពាក្យពន្យល់

ទិសឧត្តរ = (ម. ថ. – អ៊ុត - ដ) ន. ទិសខាងជើង ។

សហគិរី = (ម. ថ. សៈ ហៈ –) ន. ប្រជុំនៃភ្នំ, ពួកនៃភ្នំ ។

ទិសនិរតី = (ម. ថ. – និ រៈ ដី) ន. ទិសជាចន្លោះទិសខាងត្បូងនឹងទិសខាងលិច ។

ភូមិភាគ = (ម. ថ. ភូ - មិភាក) ន. ប៉ែកផែនដី, ទីដំបន់, កន្លែង ។

រុក្ខលតាជាត = (ម. ជ. –លៈ តា –) ន. ពួកឈើ

និងវល្លិ ៗ

សម្បូរណភាព = (ម. ជ. –៉ៈ ណៈ –) ន. ភាពនៃ

សេចក្តីគ្រប់គ្រាន់, ភាពនៃសេចក្តីពេញលេញពោរពាស ៗ

បឋមសម័យ = (ម. ជ. ប៉ៈ ឋំ មៈ សៈ ម៉ៃ) ន. សម័យ

ជាដំបូង ៗ

មហាគិរី = ន. ភ្នំធំៗ ៗ

អាកាសវេហាស៍ = (ម. ជ. –វេហ៊ា) ន. លន្វែកមេឃ,

លន្វែកអាកាស ៗ

ឫទ្ធិអានុភាព = ន. ឫទ្ធិនិងអំណាច ៗ

គេហដ្ឋាន = (ម. ជ. គេ-ហ័ត-ឋាន) ន. ផ្ទះ ៗ

## ១. អក្ខរាវិរុទ្ធ

### ដុះ--ដុស

ដុះ= កិ. ចាប់កើត, កកើត, មានពន្លក, មានដើមដង ឡើង, ឧទា. ស្រូវដុះកន្ទ្រែស ៗ ពោតដុះកន្ទបំតារ ៗ ស្ពៃនេះដុះល្អណាស់ ៗ

ដុះ = កិ. ចំរើនឡើង, ឧទា. កោះនេះរឹតតែដុះខ្ពស់ឡើង ៗ ពុកចង្កាខ្ញុំក៏ដុះវែងដែរ ៗ

ដុស = កិ. ខាត់, រំលីង, ដំរះដោយសាប៊ូ, ឧទា. តាមក្បួនអនាម័យ, កាលបើងូតទឹក, គេត្រូវដុសខ្លួនប្រាណនឹងសាប៊ូដើម្បីឲ្យស្អាត ៗ

ទ្រុបទ្រុល= សរសេរជា: ទ្រ + ុ + ប + ទ្រ + ុ + ល, កុំសរសេរជាទ្រប់ទ្រល់ ឬ ទ្រប់ទ្រុល យ៉ាងនេះឡើយ ៗ

ផ្ទុិស = គប្បីសរសេរនឹង ស៍ ខាងចុង ។

ផ្ទុិះ = គប្បីសរសេរនឹង ះ ខាងចុង ។

ប្ដិ = គប្បីសរសេរគ្មាន ៍ ចុង ។

# ៦. ប្រយោជន៍នៃវិជ្ជា

វិជ្ជាយឹតយោងនរជនដែលថោកទាប ឲ្យបានចូលទៅជិតព្រះនរបតី ដែលគេទៅជិតបានដោយក្រ ឬមានបុណ្យធំក្រៃលែងជាងព្រះនរបតីទៅទៀត ។

វិជ្ជានាំឲ្យមានវិន័យ វិន័យនាំឲ្យបានសេចក្ដីថ្លៃថ្នូរ សេចក្ដីថ្លៃថ្នូរនាំឲ្យបានទ្រព្យសម្បត្តិ ទ្រព្យសម្បត្តិនាំឲ្យបានធម៌ ធម៌ដឹកនាំឲ្យបានសេចក្ដីសុខ ។ វិជ្ជាមានពីរយ៉ាងគឺ សស្ត្រវិជ្ជា នឹងសាស្ត្រវិជ្ជា ។ វិជ្ជាទាំងពីរយ៉ាងនេះ គួរប្រតិបត្តិសិក្សារៀនសូត្រឲ្យចេះដឹងទាំងអស់ វិជ្ជាទីមួយ (សស្ត្រវិជ្ជា) កើតឡើងដើម្បីសើចលេងជាថុកកំប្លែង វិជ្ជាទីពីរ (សាស្ត្រវិជ្ជា) បុគ្គលគួរគោរពក្នុងកាលទាំងពួង ។

ក្នុងអតីតកាល មាននគរមួយឈ្មោះបាដលីបុត្រ ស្ថិតនៅក្បែរស្ទឹងគង្គា ។ ព្រះបាទសុទស្សនៈ ទ្រង់ប្រកបដោយស្វាមីគុណគ្រប់ប្រការស្ដេចគ្រប់គ្រងនគរនោះ ។ សម័យមួយ ទ្រង់

បានព្រះសណ្ដាប់សុភាសិតដែលអ្នកប្រាជ្ញបានពោលទុក មានសេចក្ដីដូចតទៅនេះ សាស្ត្រវិជ្ជាជាគ្រឿងកាត់បង់នូវសេចក្ដីសង្ស័យជាអនេក ជាគ្រឿងបើកបង្ហាញនូវអាថ៌កំបាំង និងជាភ្នែកសម្រាប់មើលសព្វសារពើការណ៍ទាំងឡាយ អ្នកណាមិនមានសាស្ត្រវិជ្ជា អ្នកនោះទុកដូចជាមនុស្សខ្វាក់ ។

ទស្សនាវដ្ដីសម្រាប់គ្រូបង្រៀន

## ក. ពាក្យពន្យល់

នរជន = ( ម.ថ. ន:រ: ជន់) ន. មនុស្ស ។

នរបតី =( ម.ថ . ន:រប់ប៉:ឌី) ន. ក្សត្រទ្រង់ពង្ស ។

ធម៌ = ( ម.ថ. ធ័រ ) ន. ការៈដែលទ្រទ្រង់សត្វលោក គឺបុណ្យបាប សុចរិត ទុច្ចរិត ។ល។

សស្ត្រវិជ្ជា = ( ម.ថ. ស័សស្ត្ៈ- ) ន. វិជ្ជាខាងគ្រឿងអាវុធ ។

សាស្ត្រវិជ្ជា= (ម.ថ. សាស-ស្ត្រ:-) ន. វិជ្ជាខាងក្បួនតម្រា

អតីតកាល= (ម.ថ. អ:តិត:កាល ) ន. ពេលដែលកន្លង

មកហើយ ។

បាដលីបុត្រ= ន. ឈ្មោះប្រទេសមួយក្នុងផ្ដែរណ្ឌៀ កាល

សម័យបុរាណ ។

ស្វាមីគុណ= ន. គុណគួរឲ្យស្រឡាញ់ស្មោះចំពោះ ។

ទ្រង់ព្រះសណ្ដាប់= កិ. ទ្រង់បានស្ដាប់ ។

សុភាសិត = ន. ពាក្យទ្រឹមត្រូវ, ពាក្យដែលមានប្រ-

យោជន៍ គួររៀនគួរស្ដាប់ (proverbe) ។

សព្វពើការណ៍= ន. ហេតុការណ៍គ្រប់បែបគ្រប់យ៉ាង ។

១. អក្ខរាវិរុទ្ធ

អំពីព្យញ្ជនៈដែលមានជើង "ជ" និង "ត"

តាមពិត, វិធីតម្រួតព្យញ្ជនៈ, គេត្រូវតម្រួតតួរបស់វាដូច

ជា: ក វគ្គ ត្រូវនៅតាម ក វគ្គ, ច វគ្គ ត្រូវនៅតាម ច វគ្គ... តែ ចំពោះ ដ វគ្គ និង ត វគ្គ មានវិធីអានបំភ្លៃសំឡេង នាំឲ្យអ្នកសរសេរ, សរសេរខុសច្រើនគ្នា ដូចជាពាក្យថា: សន្តាន ត្រូវអានថា សន់ដាន, តែ ជើង ដ មកនៅក្រោម ន ទៅវិញ នាំឲ្យអ្នកសង្កេតច្រឡំថា ដូចម្តេចបានជា គេប្រើជើងតម្រួតខុសវគ្គគ្នាដូច្នេះ ៗ មិនមែនទេ, គឺពាក្យនេះជាពាក្យបាលី; បើគេអានជា បាលីថាស័ន-តាន: បើគេអានជាខ្មែរថា សន់ដាន ដើម្បីសម្រួលសំឡេងឲ្យពីរោះស្តាប់ ។

តែទុកជាយ៉ាងណាក៏ដោយ ក៏អ្នកសរសេរគប្បីសង្កេតជាគ្រឿងត្រិះរិះឲ្យងាយចាំដូចតទៅនេះ ៖

១. បើវានៅក្រោម «ក» វាជា «ដ» ដកប ដូចជា: ក្ដីក្ដាំ, ក្ដៀង, ក្ដៅក្ដួល ។ល។

២. បើវានៅក្រោម «ខ» វាជា «ត» ដូចជា មេមាន់ខ្តតរកពង (មានតែ១ម៉ាត់នេះទេ) ។

# ៧. វិជ្ជានឹងចរិយា

ការរៀនបានផលត្រឹមតែចេះដឹង មិនហួសពីចេះដឹងទៅទៀតទេ ៗ រៀនទៅចេះតែប៉ុណ្ណោះ អ្នករៀនចេះដឹងហើយ ទោះក្មេងក្ដី ទោះចាស់ក្ដី រមែងមាននិស្ស័យសន្ដានចិត្តទៅតាមប្រក្រតីដើម ៗ អ្នកប្រមឹកនៅតែប្រមឹកដដែល ព្រោះជាអានុភាពនៃការចេះដឹង មិនអាចបន្ទន់និស្ស័យសន្ដានចិត្តនរជន ដែលចេះដឹងឲ្យទោរទន់ទៅតាមការចេះដឹងដោយឯកឯងបានឡើយ ៗ តែដោយការចេះដឹងនេះជាបច្ច័យ នរជនទើបប្រតិបត្តិអប់រំនិស្ស័យខ្លួនឲ្យមានចរិយាល្អបាន ៗ នរជនណាចេះហើយ មិនប្រតិបត្តិអប់រំនិស្ស័យខ្លួនឲ្យមានចរិយាល្អទេ, ចរិយាអាក្រក់នៃនរជននោះ ចេញមកខាងក្រៅបង្ហាញឲ្យគេឃើញច្បាស់ បានជាគេពោលថា “ចេះដឹងហើយម្ដេចក៏នៅប្រព្រឹត្តិអាក្រក់ទៀត?„ ៗ វិញ្ញូជនអ្នកចេះដឹង បើឥតចរិយាល្អតើនឹងធ្វើអ្វីកើត? ដូចដាវមុតនៅក្នុងស្រោម ៗ ប្រទេស

ជាតិចំរើនដោយសារតែពលរដ្ឋមានចរិយាល្អ ប្រទេសវិនាសក៏ព្រោះតែឥតចរិយាល្អ ។ ចរិយាល្អនេះមានតម្លៃប្រសើរបំផុត ។ ចរិយាគឺអ្វី? ការប្រព្រឹត្តទៅតាមគន្លងធម៌ ការប្រព្រឹត្តសេចក្ដីល្អទៅតាមទំនងខ្លួនជាមនុស្ស ដំកល់ខ្លួនឲ្យនៅក្នុងមនុស្សធម៌ មានកាយវាចាចិត្តស្ងប់សុភាពរៀបរយ មានមេត្តាករុណាចំពោះសត្វ ព្យាយាមរៀន ព្យាយាមធ្វើការ មានះក្នុងការងារ មានសច្ចៈក្នុងការងារ ។ល។ ទាំងអស់នេះហៅថា ចរិយា ។

## ៣. ពាក្យពន្យល់

និស្ស័យ= (ម.ថ. និស-ស៊ៃ) ន. ធម៌ជាទីអាស្រ័យ ។

សន្តាន= (ម.ថ.សន់-ដាន) ន. ចិត្ត, អធ្យាស្រ័យ, គំនិត ។

បច្ច័យ= (ម.ថ. ប៉ុច-ចៃ) ន. ហេតុជាទីអាស្រ័យគ្នា, លំអាន, ហេតុដែលនាំឲ្យប្រព្រឹត្តទៅ ។

ប្រតិបត្តិ= (ម.ថ.ប្រត៑-ប័ត) កិ. ប្រព្រឹត្ត, ធ្វើតាម, កាន់ ។

អប់រំ= កិ. បង្ហឹកចិត្ត, ទំព្រឹនបំពេញចរិតសម្រេយឲ្យបរិបូណ៌ ។

វិញ្ញូជន= ន. អ្នកប្រាជ្ញ (Savant) ។

វិនាស= កិ. អន្តរាយ, បាត់បង់ ។

មនុស្សធម៌= ន. ធម៌សម្រាប់មនុស្ស (ច្បាប់សម្រាប់ប្រដៅពួកមនុស្សឲ្យប្រព្រឹត្តសុចរិត) (humanité) ។

សុភាព= គុ. ទន់ភ្លន់, សុតបូត, របៀបរយ ។

មានះ= កិ. អត់ធន់ដោយការប្រឹងប្រែង ។

១. អក្ខរាវិរុទ្ធ

៣. បើរៅនៅក្រោម « ធ » វាជា « ដ » ដូចជា:

ឆ្អៀ= ត្រីឆ្តោ ។

ឆ្អៀរ= មាសឆ្តោរ ។

៤. បើវានៅក្រោម «ណ» វាជា « ដ » ដកាប ដូចជា:

កណ្ដៀងកណ្ដោប , កណ្ដុបនៅកណ្ដាលវាលស្រែ , បណ្ដែតទូកកណ្ដាលទន្លេ, បណ្ដុះស្រូវយ៉ាងល្អបណ្ដាច់ ។ល។

៥. បើវានៅក្រោម «ន» វាជា «ត» ដូចជា:

ចិនកន្ដាំង, បន្ដោងពេជ្រ, បន្ដឹងជើងខោ ។ល។

លើកលែងតែពាក្យទាំងនេះចេញ ដែលវាត្រូវអានជា «ត» គឺ:

ចិត្ត= សេចក្ដីគិត (pensé) ។

ពុទ្ធន្តរ= ចន្លោះកាលរបស់ព្រះពុទ្ធ ។

លោកន្តរ= ចន្លោះកាលនៃលោក ។

សន្តាន= តំណវង្ស; ពូជពង្ស (parenté, consanguinité) ។

សន្ដោស= សេចក្ដីពេញចិត្តចំពោះរបស់ដែលខ្លួន

មាន, ឧទា. ធម៌សន្ដោស, ចិត្តសន្ដោស (compassion; pitié)

## ៨. បបក នឹង ដំរី

មានសត្វបបកទាំងឡាយដ៏ច្រើន អាស្រ័យនៅលើកោះមួយកណ្ដាលសាគរ ថ្ងៃមួយនិយាយប្រឹក្សាគ្នាថា យើងជាសត្វអាស្រ័យសាច់សត្វជាអាហារ ស្វែងរកអាហារបានដោយក្រ ពោះជាបានខ្វះសោតក៏ពុំបរិបូណ៌ ហេតុនេះគ្នាយើងគួរតែទៅនិយាយលលួងបញ្ឆោតដំរីសារធំ ឲ្យវាបុះកលយើងៗ នឹងបានសាច់ដំរីនោះបរិភោគដោយបរិបូណ៌ ៗ ហ្វូងបបកគិតឃើញៗព្រមមួយហើយ ទើបនាំគ្នាបោលទឹកទៅកាន់ត្រើយស្ទឹង ចូលទៅកាន់សំណាក់នៃដំរីសារ ដល់ហើយក៏ធ្វើកិរិយាជាអ្នកកោតខ្លាច ទុនសំរសាបុះ គំនាប់គោរពដំរី ហើយស្រដីថាបពិត្រលោកជាធំដ៏ប្រសើរ សូមលោកមេត្តាប្រោសដល់ពួកយើងខ្ញុំ ៗ ដ្បិតយើងខ្ញុំទាំងឡាយសព្វថ្ងៃនេះ ឥតមាននាយចៅហ្វាយនឹងជួយការពារក្ដីអន្តរាយបាន ៗ ឥឡូវបានប្រឹក្សាគ្នាឃើញថាព្រះតេជគុណនេះជាសត្វធំឧត្តម សមគួរជានាយ

យើងខ្ញុំទាំងឡាយ ៗ យើងខ្ញុំប្រគល់កាយជាបាវបំរើព្រះតេជព្រះគុណ ចាប់ដើមពីថ្ងៃនេះតទៅ ៗ

ឯដំរីសារត់តបញ្ញា បានឮបបកទាំងនោះមកនិយាយបញ្ឆោតដូចនោះ ក៏ត្រេកអរស្រុះស្រួលទទួលជានាយលើហ្វូងបបក ៗ

ឧកញ៉ាសុតន្តប្រីជាឥន្ទ

### ៣. ពាក្យពន្យល់

សាគរ = (ម.ថ. – គៈ រ) ន. សមុទ្រ (mer) ៗ

ប្រឹក្សាគ្នា = កិ. ពិគ្រោះគ្នា, គិតគូរ, ជំនុំគ្នា ៗ

ភក្សាហារ = (ម.ថ. ភក - សា - ហា) ន. ចំណីអាហារផ្សេង ៗ ៗ

ដំរីសារ = ន. ដំរីស្ត ឬ ដំរីដែលមានភ្លុកធំអស់ទំហឹងហើយ ៗ

កល = (ម.ថ. កល់) ន. ឧបាយយ៉ាងល្អិត, ល្បិច ៗ

ឧបាយ = ល្បិច, កិច្ចកល ៗ

សិរសា = ន. ក្បាល ។

បពិត្រ = អា.និ. ពាក្យសម្រាប់ហៅចំពោះអ្នកមានសីល អ្នកធំ ។

បញ្ញា = ន. ធម្មជាតជាគ្រឿងដឹងច្បាស់ (intelligent) ។

១. អន្តរាវក្រុទ្ធ

អន្តរកប្ប = កើតជាឈ្មោះវាយកាប់ចាក់គ្នា ពាក្យដើរ (អា អន្តរកប្ប) ។

អន្តរធាន = ការបាត់បង់; សេចក្ដីវិនាស (perdu; disparu; détruit) ។

៦. បើវានៅក្រោម «ស» វាជា «ដ» ផងជា «ត» ផង, ផ្ទុកខាង «ដ»

(១) ស្ដ = ដំរីស្ដ, ដូងស្ដ, ខ្វស្ដ ។

(២) ស្ដន = ដោះ, កន្ទ្រាមដោះ (ព្រះស្ដនបុស្សផន់) ។

(៣) ស្តម្ភ= (ស្តំ)ន.សសរ ។

(៤) ស្តម្ភ= (ស្តំ) គុ.ឬ ន. រឹងត្អឹង, មាំមួន; អ្នករឹងត្អឹង, (សសរស្តម្ភ; មានទ្រព្យសម្បត្តិស្តុកស្តម្ភ) ។

(៥) ស្តាប់= កិ. ប្រុងត្រចៀកឲ្យឮ (ស្តាប់លោកគ្រូពន្យល់) ។

(៦) ស្តាយ= កិ. នឹកអាល័យ, បំពាក់ដោយអាល័យ (ស្តាយរបស់នោះណាស់ ព្រោះវាជាកេរ្តិ៍មរតករបស់ឪពុកខ្ញុំ) ។

(៧) ស្តារ= កិ. បាចទឹកចេញ (ស្តារទូក) ។

(៨) ស្តី= កិ. និយាយ (សួរហើយម៉េចក៏មិនស្តី?) ។

(៩) ស្តី= ន. ឈើមួយយ៉ាង (ដើមស្តី) ។

(១០) ស្តឹង= កិ.វិ. ឬ គុ. ដែលសំដឹងខ្លួនឥតកំរើក (ឈរស្តឹង; ក្មេងស្តឹង) ។

## ៩. ទិវានិងរាត្រី

ផែនដីមានរាងជាដុំមូល ហើយមិនមែនឋិតនៅនឹងថ្កល់ក្នុងផ្ទៃអាកាសទេ ។ ផែនដីគោចរជុំវិញព្រះអាទិត្យក្នុងកម្លុងពេលដែលយាត្រាប្រជុំខ្លួនឯង ។ ចលនានេះជាឫសគល់នៃវដ្តទាំងឡាយនៃទិវានិងរាត្រី ។ ក្នុងរយៈពេលដែលវិលប្រជុំខ្លួនឯង, ផែនដីបង្ហាញចំណុចផ្ទៃរបស់ខ្លួនបន្តិចម្តងៗទៅកាន់ព្រះអាទិត្យ ។ ចំណែកផែនដីដែលទទួលស្រូបយកសូរ្យសែងហៅថា ទិវា ឯចំណែកមួយទៀតដែលងងឹតហៅថា រាត្រី ។

កាលវេលាដែលផែនដីធ្វើចលនាបានមួយជុំ មានចំនួនម្ភៃបួនម៉ោង គឺមួយថ្ងៃនិងមួយយប់ ។ យើងពុំអាចមើលឃើញនូវចលនាផែនដីទេ ព្រោះផែនដីលាតសន្ធឹងធំធេងក្រៃលែង ហួសទស្សនវិស័យពន់ពេក ។ ដូច្នេះ យើងស្មានថាផែនដីស្ថិតនៅស្ងៀមឥតកំរើក ព្រះអាទិត្យទេតើ ដែលគោចរជុំវិញ

ផែនដី ។

យើងចង់ធ្វើទស្សនាការបំពោះចលនាផែនដី គេត្រូវបើកបញ្ញាចក្ខុជាគ្រឿងស្ទាបស្ទង់ចំងប្រមាណមិនផ្អែកគ្នាពីការពិនិត្យស្ថានសួគ៌ ឬ ស្ថាននរកទេ ។ ឯវិទ្យាសាស្ត្រ សន្និដ្ឋានផ្ទុយពីនេះទៅវិញ ព្រោះមនុស្សអស់នេះប្រាសចាកបញ្ញាចក្ខុដោយពិត ។ ផែនដីគោចរជុំវិញព្រះអាទិត្យ ក្នុងកម្មង់បីរយហុកសិបប្រាំថ្ងៃ ។

ឈិម-សំផុន

## ក· ពាក្យពន្យល់

ទិវា = ន. ថ្ងៃ (jour) ។

រាត្រី = ន. យប់ (nuit) ។

នឹងថ្កល់ = កិ. នឹងស៊ប់, នឹងឥតកំរើក ។

លង្វែកអាកាស = ន. ចន្លោះមេឃ ។

គោចរ = កិ. ដើរត្រចចរទៅ ។

ទ្វិបលតា = ន. ការកំរើកពីរបែប ។

សូរ្យសែង = (ម.ថ.សូរសែង) ន. កំដៅថ្ងៃ, ពន្លឺថ្ងៃ ។

ទស្សនវិស័យ =(ម.ថ. ទស់-សៈន៉ៈ – ) ន. ចម្ងាយដែលភ្នែកអាចមើលឃើញបាន ។

ទស្សនាការ=( ម.ថ.ទស់–សៈនា៉– )ន. អាការដែលឃើញច្បាស់, លក្ខណៈនៃការឃើញ ។

បញ្ញាចក្ខុ = ន. ភ្នែកពោលគឺបញ្ញា ។

វិទ្យាសាស្ត្រ =(ម.ថ. – សាស) ន. ក្បួនសម្រាប់រៀននូវវិជ្ជាផ្សេង ( sciences ) ។

សន្និដ្ឋាន = (ម.ថ. សន់-និតឋាន) កិ. ស្មានដោយការចូលចិត្ត ។

## ខ. អក្ខរាវិរុទ្ធ

(១០) ស្ដឹង=ន. ប្រដាប់សម្រាប់សន្ទឹងសាច់សំពត់ឲ្យតឹងស្មើ ប្រើក្នុងការប៉ាក់ (ដេរឈើស្ដឹង; ស្ដឹងប៉ាក់) ។

(១១) ស្ដឹង=កិ. លាតលាសន្ទឹងឲ្យតឹងដោយគ្រឿងរឹត (ស្ដឹងសាច់សំពត់) ។

(១២) ស្ដឹត=គុ. ដែលប្រឡឺតខឺត (កងស្ដឹត) ។

(១៣) ស្ដុក=គុ. ទ្រុបទ្រុល (ដំណាំស្ដុក, ព្រៃស្ដុក) ។

(១៤) ស្ដុកស្ដុរ=ន. ឈើធំមួយយ៉ាង ។

(១៥) ស្ដូក=កិ. វិ. ឬ គុ. កបស្ដឹងតែកំរើក (ដេកស្ដូក, រឹងស្ដូក, វែងស្ដូក) ។

(១៦) ស្ដួច=គុ. រៀវតូច (ធំគល់ស្ដួចចុង) ។

(១៧) ស្ដើង=គុ. តិចកម្រាស់ (សំពត់ស្ដើង) ។

(១៨) ស្ដៀង=ន. ខ្សែវែងសម្រាប់ចងពាក់សំពត់ (ខ្សែស្ដៀន ឬ ខ្សែស្បៀង) ។

(១៩) ស្ដៀង=ន. ខ្វាំង (តឹងស្ដៀន) ។

(២០) ស្ដៀង=គុ. ស្ទង់ឲ្យតឹង (យកឈើស្ដៀនឲ្យណែន) ។

(២១) ស្ដប=ន. ក្បត្រ), ស្ដបប៉ិតៈលើព្រះរាជបល័ង្ក)។

(២២) ស្ដបបង់ =

(២៣) ស្ដបដើរ ។

(២៤) ស្ដបក្រាញ់ ។

(២៥) ស្ដបង្អិ ។

(២៣) ស្ដែង= កិ. វិ. ជាក់ច្បាស់ពេក (ធ្វើឲ្យឃើញស្ដែង) ។

## ១០. សត្វលាពាក់ស្បែកសិង្ហ

ក្នុងកាលយូរណាស់មកហើយ ពាណិជម្នាក់បានយកលាទាំអីវ៉ាន់ទៅលក់ក្នុងទីផ្សេង ៗ ។ ពាណិជនោះបានទៅដល់ចំណាក់នីមួយ ៗ គាត់ដាក់បន្ទុកទ្រព្យអំពីខ្នងលា ហើយបំពាក់ស្បែកសិង្ហឲ្យលា រួចលែងឲ្យដើររកស៊ីក្នុងស្រែស្រូវសាលី-ស្រូវខ្សាយ-ស្រូវតាំងឡាយ ៗ ថ្ងៃមួយក្រោយមក, ពាណិជនោះឯងបានចូលទៅសំណាក់នៅក្នុងស្រុកមួយ ហើយឲ្យគេចំអិនអាហារព្រឹក ក៏បំពាក់ស្បែកសិង្ហទឹងសត្វលា រួចលែងឲ្យដើររកស៊ីក្នុងស្រែមួយដូចមុនទៀត ។

អ្នកម្ចាស់ស្រែ ដោយសំគាល់ថាសត្វសិង្ហក៏មិនហ៊ានចូលទៅជិតរួចរត់ទៅផ្ទះប្រាប់គ្នីគ្នា ។ អ្នកស្រុកទាំងអស់បានកាន់យកអាវុធផ្សេង ៗ ដែលសំលៀងយ៉ាងមុតហើយជុំប្អូនវាយស្គរប្រគុំហៅគ្នា សំដៅទៅកាន់ស្រែដែលសិង្ហបន្លំនៅកំពុងស៊ី ៗ សត្វលាដោយខ្លាចស្លាប់ ក៏ស្រែកសម្រែកដូចជា

សត្វលា ។ អ្នកស្រុកទាំងនោះដឹងច្បាស់ថា វាជាសត្វលា ដូច្នោះ ក៏វាយសំពងផ្ចាក់អស់ដំងំថ្ងៃ ហើយក៏កាន់យក ស្បែកសិង្ហត្រឡប់ទៅវិញ ។

ឝ. ពាក្យពន្យល់

សត្វលា= ន. សត្វចតុប្បាទពួកមួយ មានសណ្ឋានដូចសេះ ស៊ីកត្រចៀកវែងៗ ខ្លួនទាប (âne) ។

សិង្ហ= ន. សត្វចតុប្បាទពួកមួយ ជាម្រឹគមានអំណាចអង់ អាច (lion) ។

ពាណិជ= (ម.ថ.ពានិច) ន. អ្នកលក់ដូរ, អ្នកជំនួញ, ឈ្មួញ (commerçant) ។

បង្វៀប=(ម.ថ. បង់វ៉ិច)ន. សំណុំគ្រសោបដែលវេចអ្វីផ្សេងៗ

អាវុធ= ន. គ្រឿងប្រហារ ។

សំពង = កិ. វាយពេញកំឡាំងដៃ ដោយដំបងឬកំណាត់

ឈើផាដើម ។

## ១. អក្ខរាវិរុទ្ធ

(២៧) ស្ដោះ = កិ. បញ្ចេញទឹកមាត់ចោល (កុំស្ដោះទឹកមាត់លើកម្រាល ឬ ឥដ្ឋ) ។

(២៨) ស្ដៅ = ន. ឈើមួយយ៉ាង (អន្ទក់ស្ដៅ) ។

(២៩) ស្ដៅ = កិ. ដាក់ចំណងចងទប់គ្រាន់ឲ្យរឹងបណ្ដោះអាសន្ន (ស្ដៅស្ដី) ។

(៣០) ស្ដៅ = កិ.វិ. (ន.ប្រ.) និយាយជាគម្រាយដំបូង (និយាយស្ដៅមើលសិន) ។

(៣១) ស្ដាំ = ន. ឬ គុ. ដៃលទីទៃពីឆ្វេង, (ដៃស្ដាំ, ខាងស្ដាំ)

## ផ្នែកខាងដើម "ត"

(១) ស្ដួត = គុ. យារស្ដួត (ក្រមាយារស្ដួត) ។

(២) ស្ដនិកសត្វ ឬ ស្ដនិសត្វ = ន. សត្វមានដោះ ។

(៣) ស្ដា = កិ. វិ. ដែលចេញលំនាំខ្ពត (ដើរស្ដាប៉ុះ ស្ដាទៀន ។

(៤) ស្ដឹក = កិ. វិ. ស្រគឹកជ្រលៀក (ដេកស្ដឹក, ដួលស្ដឹក) ។

(៥) ស្ដុតិកថា = ន. ពាក្យពោលសរសើរ ។

(៦) ស្ដុល = គុ. ដែលហើមប៉ោងត្រមុល (ពងស្ដុល, ពពុះស្ដុល, ប៉ោងស្ដុល) ។

(៧) ស្ដូប = ន. ចេតិយ (ស្ដូបវត្តកំ) ។

(៨) ស្ដេត ឬ ស្ដែត = ប. ពាក្យសម្រាប់និយាយផ្សំនឹងពាក្យស្ដត (យារស្ដេតស្ដត) ។

(៩) ស្ដែក = ប. ពាក្យសម្រាប់និយាយផ្សំនឹងពាក្យស្ដោក (ព្យែរស្ដែកស្ដោក) ។

(១០) ស្ដៅ = កិ. វិ. ដែលសោគ្រោ (មើលទៅឃើញស្ដោ) ។

(១១) ស្ដោក = កិ. វិ. ដែលយារសំគោគបុះក្រោម (ព្យសព្រែកយារផ្ទាក់ស្ដោក) ។

(១២) ស្ដោបនាការ = ន. ការសរសើរ ។

(១៣) ស្ដ្រី = ន. ភេទមួយផ្ទុយពីបុរស (បុរសស្ត្រី) ។

# ១១. សាមគ្គីធម៌

សាមគ្គីគឺការរួបរួមចិត្ត, គំនិត, កម្លាំងឲ្យមូលមិត្រចងបាច់យ៉ាងមាំឥតបែកធ្លាយ ឬ ប្រេះឆាឡើយ ជាគុណធម៌មួយដ៏ឧត្តមមានកម្លាំងយ៉ាងខ្លាំងបំផុត អាចទ្រទ្រង់ពួកក្រុមគណៈ ឬ សង្គមតូចធំ រហូតដល់មហាសង្គមពោល គឺ ជាតិ ឲ្យគង់វង់ឋិតថេររឹងដំហរឈរនៅរឹងប៉ឹង មិនឲ្យរលំរលត់រលាយទៅបានឡើយ ។

សង្គមណាក្តី ជាតិណាក្តី ដែលមានជីវិតរស់នៅបានដោយអាស្រ័យកម្លាំងនៃសាមគ្គីធម៌ នេះជាមូលហេតុ ឬ ជាឫសគល់យ៉ាងមាំ អាចទប់ទល់ដើម ពោល គឺ សង្គម ឬ ជាតិនោះៗ មិនឲ្យទ្រេតទ្រោត ឬ រលើងរលំទៅបានឡើយ ។ បើសាមគ្គីធម៌សាបរលាប រលត់រលាយដោយប្រការណាហើយ សង្គមក្តី ជាតិក្តី តោងតែវិនាសអន្តរាយទៅតាមផងជាប្រាកដ ដោយឥតជម្នជាតិអ្វីទប់ទល់បានឡើយ ។

ប្រទេសកម្ពុជាយើងពីអតីតកាល ដែលបានចំរើនថ្កុំថ្កើងរុងរឿងសម្បូណ៌សប្បាយគ្រប់យ៉ាង ប្រកបដោយបុទ្ធានុភាពខ្លាំងពូកែក្រៃលែង បានពង្រីកអាណាចក្រយ៉ាងធំទូលាយ ជាមហាអំណាចទីបី ល្បីកេរ្តិ៍ឈ្មោះទៅក្នុងសកលលោក សឹងប្រាកដនៅក្នុងប្រវត្តិសាស្ត្រ ជាភស្តុតាងស្រាប់ នោះក៏មកពីកម្លាំងសាមគ្គីធម៌ដ៏ខ្លាំងក្លា ដែលផុះផុលក្នុងសន្តានចិត្តនៃបុព្វបុរសខ្មែរយើងដែរ ។

## ៣. ពាក្យពន្យល់

សាមគ្គីធម៌= ន. សេចក្តីព្រមព្រៀងដែលទុកជាធម៌ដ៏សំខាន់ ។

មហាសង្គម= ន. សង្គមធំ, ក្រុមធំ ។

មូលហេតុ= ន. ហេតុដែលជាបុសគល់ ។

ប្រការ= ន. ចំពូក, ប្រភេទ, ទំនង, បែប, វិធី ។

តោងតែ= កិ.វិ. ត្រូវតែ, គប្បី, គួរជា ។

ប្រាកដ= គុ. ជាក់, ជាក់លាក់, ពិត, ស្ដែង ។

ឫទ្ធានុភាព= ន. ឫទ្ធិ និងអានុភាព ។

ពង្រីក= កិ. ធ្វើឲ្យរីក, ធ្វើឲ្យធំ ។

អាណាចក្រ=(ម.ជ. –ច័ក) ន. អំណាចដែលប្រព្រឹត្តទៅក្នុងមួយជុំខេត្រដែនដូចជាកង់រទេះ, អំណាចនៃការគ្រប់គ្រប់ប្រទេសមួយ ៗ ផ្សាយទៅជុំវិញប្រទេសនោះ ។

សកលលោក= (ម.ជ. ស:កល់–) ន. លោកទាំងមូល ។

ប្រវត្តិសាស្ត្រ= (ម.ជ. ប្រវ័ត–តិសាស) ន. គម្ពីរ, ក្បួនដែលសំដែងអំពីពង្សាវតារ (histoire) ។

ភ័ស្ដុតាង= (ម.ជ. ភ័ស–) ន. របស់សម្រាប់សំអាង, របស់ជាតឹកតាង ។

បុព្វបុរស= (ម.ជ. បុប–ពៈបុរ៉ស់) ន. បុរស ជាខាងដើម

វង្ស, ជីដូនជីតា ។

## ១.អក្ខរាវិរុទ្ធ

## ជិន-ជិន់-ជិន្ន

ជិន= (ម.ថ.ជន់) ន. ប្រជាប់នេសាទមច្ឆជាតិមួយយ៉ាង ។

ជិន= (ម.ថ.ជន់) សព្វសត្វដែលកើតក្នុងលោក, មនុស្ស, អ្នកផង ។

ជិន់= កិ. ឡើងសាយកាយ (ទឹកជន់) ។

ជិន្ន- (ម.ថ.ជន់) ន. អាយុ, ជីវិត ។

ឧទា. តាជេនប្រកបដោយជន្មហាសិបឆ្នាំ យកជិនទៅដាក់ត្រីស៊ក្នុងបឹង ដែលមានទឹកជន់ពេបពាសពេញ ហើយមានជនឯទៀតយកជិនទៅរកត្រីដូចគាត់ដែរ ។

# ប្រព្រឹត្ត-ប្រព្រឹត្តិ

ចូរចំណាំឲ្យមែនទែន៖

ប្រព្រឹត្ត= នេះជា កិ. ធ្វើ, ធ្វើតាម, ប្រតិបត្តិតាម ។

ឧទា. ជនដែលចេះដឹងហើយ ម្ដេចក៏នៅប្រព្រឹត្តអាក្រក់ទៀត ?

ប្រព្រឹត្តិ= នេះជា ន. (តជើងតស្រៈ ិ) ការធ្វើតាម, ការកាន់វត្តប្រតិបត្តិ ។

វិសេសនៅទៀត

ប្រតិបត្តិ=(តជើងត + ស្រៈ ិ) ដែរ ជា ន. ផង, ជា កិ. ផង ឧទា សេចក្ដីប្រតិបត្តិ, ត្រូវប្រតិបត្តិតាមច្បាប់ ។

## ១២. កំណើតនៃភ្លេង

សម័យថ្ងៃមួយ , មានកូនក្មេងប្រុសម្នាក់បានយកដើមឫស្សីមួយមកផ្លុំ ។ ស្រាប់តែសម្លេងមួយលាន់ឮឡើងយ៉ាងពីរោះ ។ មនុស្សទាំងចាស់ទាំងក្មេង ផ្អើលនាំគ្នាមកពោមមើលក្មេងនោះ ។ អ្នកខ្លះសប្បាយក្អាកក្អាយដោយបានឮសំឡេងថ្មីនេះ ។ អ្នកខ្លះភ័យក្រែងមានព្រាយអាក្រក់មកសិងនៅកងខ្លួនកុមារនោះ ។ ប៉ុន្តែទុកជាយ៉ាងណាក៏ដោយ ក្មេងក៏ចាប់កំណើតតាំងពីកាលនោះមក ។ ថ្វីត្បិតតែសំឡេងនោះនៅមានតែមួយ ប៉ុន្តែមនុស្សប្លែកអំពីសត្វត្រង់បេះដូងស្មុគស្មាញរកសេចក្តីបរិបូរណ៍ឲ្យលឿនទៅមុខ ។ ហេតុដូច្នេះហើយបានជា គេនាំគ្នារិះគិតគូរ ។ មកទៀត រហូតដល់តែអាចបង្កើតនូវគ្រឿងប្រដាប់សម្រាប់ឲ្យឮសំឡេងយ៉ាងពីរោះ ទីងអក្សរសម្រាប់កត់នូវសំឡេងនោះផង ។

ធម្មជាតិដែលជាមាតានៃវត្ថុធាតុសិល្បៈ ក៏បង្កើតឲ្យមាន

ពណ៌ប្រាំពីរ ដូចជាសំឡេងក្មេងដែរ គឺឥន្ទធនូ ។ សំឡេងក្មេងដែលកើតឡើងដំបូង ដោយសារការធ្វើត្រាប់សម្លេងធម្មជាតិ ដូចជាសម្លេង ផ្គរគ្រហឹម រន្ទះបាញ់ផូងផាង, ខ្យល់ព្យុះហ៊ូៗ និងសម្លេងសត្វយំចេបចាប, កែបកប , ហ៊ុងហាង ជាដើម ។

## ក. ពាក្យពន្យល់

ដើមបបុស = ន. ស្មៅខ្ពស់ៗ ដើមវែង មានប្រហោង ។

ព្រាយ= ន. ភូត, បិសាចពួកមួយ ដែលគេច្រើនជឿថាតែង ចូលជ្រែកយាយីមនុស្សឲ្យឈឺចាប់ ។

កុមារ = ន. ក្មេងប្រុសតូច ( enfant ) ។

វត្ថុជាតុសិល្បៈ = ការរចនានៃរបស់ដើម ។

ឥន្ទធនូ = ( ម. ថ. អិន - ធៈ នូ ) ន. ធ្នូព្រះឥន្ទ, ពន្លឺ នាផ្ទៃមេឃ មានសណ្ឋានកោងស្រដៀងនឹងកងធ្នូដែល

គេឃើតពេញកម្លាំង តែងកើតមានត្រង់ទិសផ្ទុយគ្នា នឹងវង់ព្រះអាទិត្យ ( arc-en-ciel ) ។

១. អក្ខរាវិរុទ្ធ

បញ្ញត្ត – បញ្ញត្តិ

បញ្ញត្ត = នេះជា កិ. ឬ គុ. ហាមប្រាម, តែងតាំង; ដែលបានហាមប្រាមរួចហើយ, ដែលបានតែងតាំងហើយ ។

បញ្ញត្តិ = នេះជា ន. សេចក្តីហាមប្រាម, បំរាម, សេចក្តីដែលគេតែងតាំង ។

ឧរា. រាជការបានបញ្ញត្តថា មិនឲ្យពលរដ្ឋទៅលេងល្បែងស៊ីសង, ជនណាម្នាក់ហ៊ានល្មើសនូវរាជបញ្ញត្តិនេះ នឹងត្រូវមានទោសជាទម្ងន់ ។

អនុញ្ញាត

អនុញ្ញាត = នេះជា កិ. ផង, ជា គុ. ផង នឹង ជា

ន. ផង ព្រោះវាជា នបុំសកលិង្គ ហើយវាជា ន. ទៀតនេះ ក៏វាគ្មានស្រៈ ិ ដូចជា ប្រតិបត្តិ ប្រព្រឹត្តិ, បញ្ញត្តិ ទាំងនោះឡើយ,

១៣. សេចក្ដីអនុញ្ញាត របស់លោកគ្រូ ដែលគាត់បានអនុញ្ញាតតាមខ្ញុំសុំហើយនោះ ខ្ញុំនឹងទៅតាមពាក្យអនុញ្ញាតរបស់គាត់មិនខាន ។

## ១៣. ខ្យល់ព្យុះ

ព្រះអាទិត្យបើករស្មីបំភ្លឺលោកតាំងពីព្រលឹមទល់ល្ងាច ៗ ប្រហែលជាម៉ោងមួយរសៀល មានពពកខ្មៅមួយដុំ លេចឡើងនៅជើងមេឃឯនាយ ៗ ចំណុចខ្មៅនោះរីកធំបន្តិចម្តងៗ បណ្តាលឲ្យផ្ទៃមេឃមួយចំណែកងងឹតឈ្លប់ ៗ ព្រះពាយក៏បើកបន្ទូរខ្យល់ឲ្យស្ទុះយ៉ាងខ្លាំង បើងស្លឹកឈើស្ងួត ៗ និងធូលីហុយទ្រលោម ៗ បក្សាបើកកញ្ច្រៀវខ្សៀវខ្សា ហោះព្រួយមករកទ្រនំស្ដុកស្ដម ៗ ផ្គរលាន់ស្រែកគ្រហឹមងឹល ៗ ផ្ទួន ៗ គ្នា ផ្លេកបន្ទោរឆ្នូតបន្ទាត់ភ្លែត ៗ ខ្យល់ព្យុះក៏ស្ទុះមកដល់សំដែងឫទ្ធិគួរឲ្យខ្លាច ៗ ព្រះវរុណបើកសន្ទុះទម្លាក់ដំណក់ភ្លៀងធំ ៗ រឹតតែខ្លាំងឡើង ៗ អ្នកដំណើរទាំងឡាយរត់គេចរកទីជ្រកពួនរៀង ៗ ខ្លួន ៗ

វាយោធាតុក៏ប្រឹងបក់បោកខ្លាំងជាងមុនទៅទៀត ខ្យល់ព្យុះស្ថិតនៅអស់កន្ទះម៉ោង ៗ រួចពីនោះភ្លៀងក៏រាំង ខ្យល់ក៏

ស្ងប់ មេឃក៏ស្រឡះ ព្រះអាទិត្យក៏បញ្ចាំងរស្មីមកវិញ ។

អ្នកដំណើរទាំងឡាយ ក៏ចាប់បន្តដំណើររបស់ខ្លួនទៅ លើផ្លូវថ្នល់ដ៏ពេញទៅដោយទឹកទឹងស្លឹកឈើ ។

ឈិម-សំផុន

## គ. ពាក្យពន្យល់

ព្យុះ= ន. ខ្យល់ខ្លាំង, ខ្យល់ដែលបក់បោកខ្លាំង ។

វស្សី= (ម. ពាក្យពេញក្នុងអត្ថបទសម័យអក្សរសាស្ត្រ) ។

ពពក= ន. សំណុំផ្សែងទឹកក្រាស់ឬស្តើងដែលអណ្តែត ឰដ៏អាកាស (Nuage) ។

ឯឡាយ= អា.និ. ឆ្ងាយលន្លោច, ដែលនៅឆ្ងាយ ។

ព្រះពាយ= ន. ខ្យល់ ។

ធូលី= ន. ធង់, លំអង (មានលំអងដីជាដើម) ល្អង ។

ស្តុកស្តម្ភ=(ម.ថ.-ស្តុំ) គុ. រឹងពំហរ, មាំមួន, រឹងប៉ឹង, គត់មត់

ផ្លេកបន្ទោរ= ន. ពន្លឺផ្លេកដែលចេញជាខ្សែកោងៗ ឬដាលប្រវាត់ក្នុងអាកាស ។

ឫទ្ធិ= (ម.ថ.រឹត) ន. អំណាច, សេចក្ដីអស្ចារ្យ, សេចក្ដីក្លៀវក្លា ។

ព្រះវរុណ= ន. ភ្លៀង (Pluie) ។

សត្ទុះ= ន. ប្រដាប់សម្រាប់ស្ទូះ, សម្រាប់ខ្ទប់, សម្រាប់បិទ ។

វាយោធាតុ= (ម.ថ.-ធាត) ធាតុខ្យល់ ។

១. អត្ថាវិរុទ្ធ

កំពង់ - កំពុង

កំពង់= ន. ទីកន្លែងនៅមាត់ទឹក ដែលជនានុជនចុះដងទឹកឬចតជាដើម (កំពង់ទឹក, កំពង់ទូក, កំពង់កប៉ាល់) ។

កំពុង= គុ. អ្វីៗ ដែលកំពូលកណ្ដាលឡើងខ្ពស់ជាងគៀន (ពេញកំពុង, ថ្ពាល់កំពុង) ។

កំពុង= រវាង, ចន្លោះ (កំពុងតែស៊ីបាយ, កំពុងតែរៀន) ។

បំណាំ.– ក្នុងពាក្យពីរព្យាង្គ, ព្យាង្គដើមមានសំឡេង “ុំ” ឬ “ុំ” មិនដែលមានបុះជើងឡើយ ។

ដូចជា :

កំពុង, កំពស់, គំនូរ, ដំណាក់, លំនាំ, លំអ ។ល។

លើកលែងតែពាក្យជុំវិញញាចេញ ។

# ១៤. បង់បត់

នៅទាំព្រៃភ្នំដ៏ស្ងាត់ជ្រងំគួរស្រៈនេះស្រងោច ហើយឆ្ងាយដាច់សង្វែងអំពីភូមិនៃមនុស្ស វេលាថ្ងៃ ឮសូររយំទ្រហឹងអឺងអាប់ វេលាយប់ឡើង ឮសូរសំរែកនៃសត្វសាហាវ នាំឲ្យព្រឺព្រួចរំជួលក្នុងហឫទ័យជាពន់ពេក ៗ ទីនេះហើយជាទីលំនៅនៃអ្នកបង់បត់ ក្រៅពីមនុស្សប្រកបដោយធម៌ មិនអាចហ៊ានចូលទៅប្ដូរជីវិតក្នុងភ្នំនោះឡើយ ។ បើមនុស្សសាមញ្ញណាដែលមិនមានគុណធម៌នៅក្នុងខ្លួន ហើយដើរទៅក្នុងទីរហោឋាននោះ នឹងបានជាចំណីនៃសត្វសាហាវបរិភោគពុំខាន ។

ទស្សនីយភាពនៃភ្នំ មើលពីចម្ងាយគួរឲ្យលន្លង់លន្លោច ដោយមានឈើធំស្រោងស្រាង ៗ វេលាគិម្ហន្តរដូវមើលទៅឃើញថ្ងៃបណ្ដើរកូនព្រិច ៗ ហើយវាយោបក់ប៉ុនឈើរវិច ៗ នោះសមជាទីកន្លែងវិវេកនៃលោកសង្ឃធុតង្គ ។

ឯបង់បត់នោះមិនមានរូបបដិមាដូចអ្នកតាទេ តែជាអ្នក

ល្បីល្បាញខាងពូកែនៅក្នុងព្រៃភ្នំ បានខាងសំដែងឫទ្ធិ ធ្វើឲ្យអន្តរាយដល់មនុស្សសាមញ្ញណា ដែលគ្មានគុណធម៌ហើយឥតការុង មិនឲ្យនៅទីនោះបានឡើយ ។

ទស្សនាវដ្តីសម្រាប់គ្រូបង្រៀន

## ក. ពាក្យពន្យល់

បង់បត់= ន. ទេព្រក្ស ឬអ្នកតានៅដោយព្រៃភ្នំក្រំឬ ដែលមនុស្សតែងប្រកាន់ជឿថាមានឫទ្ធិស័ក្តិសិទ្ធិ ។

ភូមិ= (ម.ថ.ភូម) ន. ទីដី, ដំបន់, ទី, ផែនដី (Village) ។

សាហាវ= គុ. កាច, មោះមុតឥតញញើត (Méchant) ។

ហឫទ័យ= (ម.ថ ហ្រឹទៃ) ន. បេះដូង, ដួងចិត្ត, ចិត្ត ។

សាមញ្ញ= (ម.ថ.សាមុញ) គុ. ដែលជាធម្មតា ដែលស្មើៗតែគ្នា, សាធារណៈ (Simple) ។

គុណធម៌= (ម.ថ.គុណៈធ័រ) ន. ធម៌ដែលមានដំណើរ

បំរើនសេចក្ដីសុខ-ទុក្ខតាមជាន់ថ្នាក់, សេចក្ដីល្អ, សេចក្ដីបរិសុទ្ធ (vertu) ។

រហោឋាន= ន. ទីស្ងាត់, ទីដែលមិនមានមនុស្សនៅ ។

ទស្សនីយភាព= (ម.ថ.ទ័ស-ស:នី យ:ភាប) ន. ភាពដែលគួរឃើញ (Aspect) ។

លន្វង់លន្វោប= គុ. ដែលឆ្ងាយសន្ទឹមគួរឲ្យលន្ទោបចិត្ត ។

ស្រោងស្រោង= គុ. ដែលខ្ពស់ៗ សន្ទឹម ។

គិម្ហន្តរដូវ= (ម.ថ. គិមហ័នត:–) ន. បុនរដូវក្ដៅ ។

វាយោ= ន. ខ្យល់ (vent) ។

វិវេក= គុ. ស្ងាត់, ដែលស្ងាត់ចាកអារម្មណ៍សៅហ្មង ។

ធុតង្គ ឬធូតង្គ= (ម.ថ. ធុដុង ធូដូ-) ន. អង្គរបស់ធម៌ជាគ្រឿងកំចាត់បង់នូវកិលេស ។

បដិមា=(ម.ថ.ប៉ៈដិម៉ា) ន. រូបសំណាក, រូបប្រៀប, រូបដំណាង ។

១. អក្ខរាវិរុទ្ធ

អំពីស្រៈ ំ និង ុំ ដែលមាននៅលើអក្សរឃោសៈ

គំ - គុំ

គំ= កិ. ចាក់ទឹកត្រាំបាតឆ្នាំង ដើម្បីឲ្យរបើកបាយក្តាំង (គំទឹក) ។

គំ= ន. បាយដែលគេចាក់ទឹកគំរបើកបានមកហើយ (បាយគំ ឬ បាយគំទឹក) ។

គុំឬគុម= កិ. ប៉ងដោយអាក្រក់, ចងគំនំ, (អ្នកមួយធ្វើបាបអ្នកមួយ គុំរាយវិញ) ។

គុម្ព=(ម.ថ.គំ) ន. ពូក, ប្រជុំ ដើមឈើឬដំណាំផ្សេងៗ (គុម្ពឈើ, អំពៅ ១ គុម្ព) ។

ចំពោះអក្សរ ឃំ មានប្រើតែឃ្មុំប៉ុណ្ណោះ ចំណែកឃំ យ៉ាងនេះគ្មានឡើយ ។

ដូចជា: ឃុំ, ឃ្លុំ, ឃ្មុំ ។

គ្មាន ឃំ, ឃ្លំ, ឃ្មំ ឡើយ ។

ចំពោះអក្សរ ជំ មានតែ ពាក្យ ជំ (ថ្ងាយធំ) នេះមួយប៉ុណ្ណោះ ។ ចំណែកជ្រុំគ្មានសោះ ។

ជំ-ជុំ

ជុំ មានប្រើតែពីរពាក្យប៉ុណ្ណោះគឺ:

ជុំ= កិ. ឬ កិ. វិ. មូលគ្នា (គេមកជុំគ្នាហើយនៅ?) ។

ជុំ= ន. ដំណើរវង់វិលជួបមកកន្លែងដដែលវិញ (ដើរប្រទក្សិណបីជុំព្រះវិហារ) ។

ជុំកន្លង់= ន. ឬ គុ. ឈ្មោះល័ខមួយយ៉ាង (ល័ខជុំកន្ទង់) ។

ក្រៅពីពាក្យទាំងនេះចេញ  សុទ្ធតែប្រើជំទាំងអស់,

ដូចជា:

ជំងឺ, ជំទប់, ជំទាវ, ជំទាស់, ជំនន់, ជំនាន់,

ជំនុំ ។ល។

# ១៥. ធ្វើគុណបានទោស

នៅផ្លូវទៅកាន់នគរឈ្មោះឧជ្ជេនី, មានដើមជ្រៃក្រឹមមួយដើម ដុះនៅកន្លែងព្រៃមួយ មានសត្វបក្សីពីរ គឺហង្ស១, ក្អែក១, នៅជាមួយគ្នា ។ ថ្ងៃមួយ មានបុរសម្នាក់ ធ្វើដំណើរតាមផ្លូវ, ហត់អស់កំឡាំងដោយត្រូវកំដៅថ្ងៃ ក៏ចូលទៅជ្រកនៅក្រោមដើមឈើនោះ ហើយដាក់ធ្នូរបស់គាត់នៅក្បែរខ្លួន រួចហើយក៏ប្រះដេកនៅក្រោមម្លប់ឈើនោះឯង ។ មិនយូរប៉ុន្មាន ម្លប់ឈើក៏ឃ្លាតចេញពីមុខរបស់គាត់ ។ សត្វហង្សដែលទំនៅលើដើមឈើនោះ លុះឃើញពន្លឺព្រះអាទិត្យចាំងចំមុខបុរសនោះដូច្នោះ ក៏ត្រដាងស្លាបរបស់ខ្លួន ដើម្បីការពារកំដៅថ្ងៃកុំឲ្យចាំងលើបុរសនោះ ដោយសេចក្ដីករុណាគតអាសូរចំពោះគាត់ ។

ដោយការលំបាកតាមផ្លូវ បុរសនោះដេកលក់យ៉ាងស៊ប់ ហើយបំហមាត់ ។ សត្វក្អែកជាសត្វដែលតែងតែបំផ្លាញខូវសេចក្ដីសុខរបស់សត្វដទៃ បានឃើញបុរសនោះដេកបំហ

មាត់ដូច្នោះ  ក៏ជុះអាចម៍ដាក់បំមាត់គាត់រួចហើរបាត់ទៅ ៗ បុរសនោះភ្ញាក់ឡើងក្រឡេកទៅឃើញសត្វហង្ស  ក៏នឹកថា: «យីអាសត្វចង្រៃនេះ ដូចម្ដេចបានជាហ៊ានជុះអាចម៍ដាក់មាត់អញដូច្នេះ ៗ អញនឹងបាញ់វាសម្លាប់ចោលចេញ» គិតហើយក៏ដម្លើងធ្នូរបស់គាត់បាញ់ហង្សនោះស្លាប់ទៅ ៗ

ក. ពាក្យពន្យល់

ទោស= ន. កំហុស, សេចក្ដីប្រទូស្ដ, សេចក្ដីមិនល្អ (faute)

នគរ= (ម.ប. ន–គ) ន.បុរី, ក្រុង ៗ

ឧជ្ជេនី= (ម.ប. ឧជ-ជេនី) ឈ្មោះនគរមួយក្នុងប្រទេសឥណ្ឌាសម័យបុរាណ ៗ

ជ្រៃក្រឹម= ន. ឈ្មោះជ្រៃមួយយ៉ាងដើមតូចស្លឹកតូច ៗ ៗ

បក្សី= (ម.ប. ប័កសី) ន. សត្វស្លាប (oiseau) ៗ

ហង្ស= (ម.ប. ហង់) ន. ក្ងានព្រៃ, សត្វបក្សីមួយយ៉ាងរូបកាយ

ដូចគ្នា ។

ធ្នូ= ន. អាវុធធ្វើដោយឈើ, ឫស្សីឬគ្រាំង មានដងមាន

បន្ទោះសម្រាប់បាញ់ដោយព្រួញ ។

ប្រែះ= កិ. ផ្អៀងខ្លួនដេក, រំលើខ្លួនឬផ្ដួលខ្លួនដេក ។

អាសូរ= កិ. អាណិតទន់ចិត្ត, អាណិតខ្លោចចិត្ត ។

១. អក្ខរាវិរុទ្ធ

ចំពោះអក្សរ ឈ គ្មានប្រើពាក្យ ឈុំ ឬឈំឡើយ ។

ចំពោះអក្សរ ញ មានប្រើតែពាក្យញុំ ។ នេះមួយម៉ាត់ប៉ុណ្ណោះ (ទុំញាំញុំៗ) ។ ចំណែកញុំគ្មានប្រើឡើយ ។

ញុំ-ញុំ

ញុំ= (ម.ថ. ញ៉ម់) កិ. ធ្វើម្ហូបដែលហៅថាញាំ (ល្ងាចនេះខ្ញុំញាំទទួលទានហើយ) ។

ញុំ= (ម.ប. ញ៉ម់) ន. ឈ្មោះម្ហូបមួយយ៉ាង (ញាំត្រ-

សក់, ញាំសាឡាត់, ញាំមាន់) ។

ញុំា= (ម.ថ. ញ៉ាម់) កិ. ស៊ី (ពាក្យទំលើ) (អានាង ! មកញុំាបាយ) ។

ចំពោះពាក្យញុំាំង, អ្នកសរសេរច្រើនតែសរសេរជា ញាំង, ដូចនេះ ប្អូនសង្កេតឲ្យជាក់ថា ពាក្យញុំាំង នេះ សរសេរបានតែ ញុំាំងមួយយ៉ាងប៉ុណ្ណោះ ។

## ទុំ - ទំ

ទុំ= គុ. ទីទៃពីខ្ចីពីចាស់ (ផ្លែឈើទុំ, ពោតទុំ) ។

ទុំ= ប. ពាក្យសម្រាប់និយាយផ្សំនឹងពាក្យចាស់ (ខ្ញុំជាមនុស្សចាស់ទុំហើយ) ។

ទំ= កិ. បិតលើទ្រនំ (សត្វព្រាបទំលើដំបូលវិហារ) ។

ទំ= កិ. ចាប់ឈើមិនស្រាកស្រាន្ត (ពោតទំ, ដំនឹទំ) ។

ទំ= កិ. (ន.ប្រ.) នៅជាមួយនឹងប្រពន្ធដែលស្ដុកស្ដម្ភ

(ខ្ញុំទំមិនដាប់ទេ ) ។

ទុំ= ដែលទំនៅមិនស្រាក (ទុក្ខទំ) ។

# ១៦. អាហារនិងសុខភាព

ចំណីអាហារល្អ គឺជាការប្រសើរមួយដល់សុខភាពល្អ។ អាហារដែលយើងបរិភោគ អាចធ្វើឲ្យយើងមានកំឡាំងហើយរស់នៅបាន ។ ដូចជាខាងគ្រឿងយន្តផ្សេង ៗ ក៏ដូចោ្នះដែរ ដើម្បីនឹងបានផលល្អអំពីម៉ាស៊ីននោះ យើងត្រូវតែឲ្យម៉ាស៊ីននោះឯងនូវគង់នឹងប្រេង បើប្រេងល្អហើយគប់គ្រាន់ផង នោះម៉ាស៊ីនក៏រត់បានស្រួល ។ គេចែកចំណីអាហារដែលយើងត្រូវបរិភោគជានិច្ចជាកាលជាពួក គឺ: មើមស្ពៃក្រហម, សណ្តែកខៀវ, សណ្តែកលឿង, ពោត, ត្រឡាច, ប៉ុកគក់, ត្រសក់, សាឡាត់, ស្ពៃ, ជី, ម្រេច, ម្ទេស, ត្រប់, ស្វាយ, ស៊ុកជន្ទីង សណ្តែកបារាំងស្រស់, ស៊ុកខ្ទឹមបារាំង ពួកមួយ; ស្ពៃក្តោប, ក្រូចថ្លុង, ក្រូចពោធិសាត់, ក្រូចឆ្មារ, ប៉េងប៉ោះ ពួកមួយ;ចេក, ដំឡូងបារាំង, ផ្លែល្ហុង, ផ្លែស្វាយ, ផ្លែពោត, ផ្លែដូង, ម្នាស់, ប៉ោម, ទំពាំងបាយជូរ ពួកមួយ; ទឹកដោះគោស្រស់, ទឹកដោះ

គោកំប៉ុងពួកមួយ; កូនមាន់, ត្រី, សាច់គោ, សាច់ជ្រូក, ពងមាន់, សណ្ដែកស, ក្ដាម, បង្កង, បង្គា, ខ្យងសមុទ្រ, សណ្ដែកដីពួកមួយ; នំប៉័ង, នំផ្អែម, នំធ្វើពីម្សៅ, អង្ករ, ម្សៅមី, បបរពោត, ម្សៅកូរ, ផ្លាយដំណើប, អំបុក, នំគ្រៀបបំពងពួកមួយ ទឹកប្រេងដូង, បើរពួកមួយ ។ យើងត្រូវបរិភោគអាហារទាំងនេះតាមរបៀបអនាម័យ ទើបយើងមានសុខភាពល្អ ។

## ៣. ពាក្យពន្យល់

អាហារ = ន. គ្រឿងបរិភោគចំអែតកាត្ត, ភោជន (aliment)

សុខភាព = (ម.ថ.សុខៈ ភាវ) ន. ភាពជាសុខ, សេចក្ដីសុខ (santé) ។

បរិភោគ = (ម.ថ.បរិ–) កិ. ទទួលទាន, អាស្រ័យ, ហូប, ស៊ី ។

គ្រឿងយន្ត = (ម.ថ.–យន់) ន. គ្រឿងម៉ាស៊ីន ។

បង្គា = ន. គ្រោនសមុទ្រ, កំពឹសសមុទ្រ ។

ប៊ើរ = ន. ប្រហុកផាពាំង ( beurre ) ។

អធាម៉យ = ( ម:ព. កុងអត្ថបទការសិក្សា) ។

១. អក្សរពិរុទ្ធ

ធុំ-ធំ

ធុំ = កិ. ចាប់ក្លិន, ជាន់ក្លិន (ធុំក្លិនក្រអូប, ធុំក្លិនស្អុយ) ។

ធំ = គុ. ទំហំពីតូច (សត្វដំរីធំជាងសត្វខ្លា) ។

ធំ = ប.ស. ពាក្យសម្រាប់កូនហៅបងប្រុស ឬបងស្រី របស់បិតាឬរបស់មាតា (អញ្ជើញធំឡើងលើផ្ទះមក) (គេច្រើននិយាយថា ឪពុកធំឬម្ដាយធំ) ។

ចំពោះអក្សរ ធំ មានប្រើតែពាក្យ ធំ (បន្ថែម) នេះមួយប៉ុណ្ណោះ ។ ចំណែកពាក្យ ធុំ គ្មានប្រើឡើយ ។

## ពុម្ព-ពុំ-ពំ

ពុម្ព= (ម.ថ. ពុំ) ន. រូបដំណាង, សំណាក (យកសៀវភៅទៅបោះពុម្ព) ។

ពុំ= និ. មិន, ឥត (ពុំស្រួល, ធ្វើដូច្នេះទៀតពុំបានឡើយ) ។

ពាក្យមួយព្យាង្គជា ពំ នេះ ពុំមានប្រើឡើយ, មានប្រើតែពាក្យពីរព្យាង្គឬច្រើនព្យាង្គ,

ដូចជា:

ពំនាក់, ពំនិត, (សេចក្ដីពិត), ពំនឹង, ពំនួត, ពំ-នួត, ពំនៀរ, ពំនោល ។ល។

ចំណែកពាក្យ ពុំ ដែលប្រើជាពីរព្យាង្គឬច្រើនព្យាង្គមានតែប៉ុន្មានពាក្យប៉ុណ្ណោះគឺ:

ពុំងា (កែវពុំងា), ពុំជូកាល, ពុំនោះ, ឬ ពុំនោះសោត, ពុំសែន (ដើមពុំសែន) ។

## ១៧. សេចក្ដីខុសឆ្គងបន្តិចបន្តួច

ចូរយើងកុំមើលងាយសេចក្ដីខុសឆ្គងបន្តិចបន្តួច ៗ
ខ្យងសោតបានធ្វើឲ្យប្រទេសហុល្លង់ដ៏ មានភ័យម្ដង
ផងហើយ ដោយចោះធ្លុះបន្ទាយទឹកដែលជាការមាំបំផុតក្នុង
លោក ៗ សេចក្ដីឆ្គាំឆ្គងសឹងជាដើមអាទិ៍នៃកំហុសដ៏ភប ៗ
អំពើពុតពាលនោះឯងក៏ជាកូននៃសេចក្ដីឆ្គាំឆ្គងដែរ ៗ
ចំណុចខ្មៅតូចកើតលើធ្មេញមួយ វាមិនធ្វើទុក្ខអ្វីទេ
តែបើអ្នកមិនឲ្យពេទ្យមើល ធ្មេញអ្នកនឹងខូចទាំងមូលពុំលែង ៗ
ហើយបើអ្នកមិនឲ្យដកយកចេញ ធ្មេញឯទៀតនឹងខូចតាម
គ្នាទាំងអស់ ៗ សេចក្ដីធ្វេសក្លាយទៅជាអំពើឆ្គាំឆ្គង ៗ អំ-
ពើឆ្គាំឆ្គងនោះតូចតាចណាស់ទេ ព្រោះអំពើនោះលាក់ទុកនូវ
កំហុស ៗ កាលណាអ្នកធ្វើខុសអ្វីមួយ ហើយអ្នកមិនហ៊ាន
ប្រាប់គេ នោះនឹងក្លាយទៅជាកំហុសមួយយ៉ាងធំ ៗ កុហក
ជាបុត្រជិតដិតរបស់ក្ដីធ្វេស តែក្ដីធ្វេសនោះពុំមែនមានតែកូនមួយ

ប៉ុណ្ណោះឡើយ ។ តាមដោយពិចារណា គេឃើញមានកូនពីរអាគ្រក់ដូចគ្នា គឺ ឥស្សាមួយនឹងឈ្នានីសមួយ ទាំងពីរនេះកើតទៅជាគំនុំគំនួច ដែលជាមេនៃគុទោស ។

ចូរអ្នកមានអធ្យាស្រ័យដល់កំហុសបន្តិចបន្តួចរបស់មិត្តសំឡាញ់អ្នក ។ ចំពោះកំហុសខ្លួនអ្នកវិញ ចូរអ្នកប្រឹងជំនះលុះត្រាតែបាន ។

ទស្សនាវដ្ដីសម្រាប់គ្រូបង្រៀន

ក. ពាក្យពន្យល់

ឆ្គង = គុ. ដែលគង, វេង, មិនគប្បី, មិនសម ។

ខ្យងសោក = ន. ឈ្មោះខ្យងមួយយ៉ាងដែលស្រដៀងនឹងខ្យងគូចស្រួច ។

ប្រទេសហុល្លង់ = ន. ឈ្មោះប្រទេសមួយដែលឋិតនៅក្នុងទ្វីបអឺរ៉ុប ។

ដើមអាទិ៍ = (ម.ថ. – អាត) ន. ដើមដំបូង ។

អំពើតុតពាល = អំពើអាក្រក់សាមាន្យ ។

កុហក = (ម.ថ. កុហក់) ន. ពាក្យដែលធ្វើឲ្យគេកំពុងជំនឿ ។

បុត្រ = (ម.ថ. បុត) ន. កូន ។

ឥស្សា = (ម.ថ. អ៊ិស-សា) ន. សេចក្ដីច្រណែន, សេចក្ដីឈ្នានីស, ប្រស្សា ។

ឈ្នានីស = ន. អំពើច្រណែន ប្រស្សាបង្អាក់ការណ៍លាក់កាន់ប្រយោជន៍គេ ។

គរុទោស = (ម.ថ. គៈរុ-) ន. ទោសលើសដ៏ធ្ងន់ (faute grave)

អធ្យាស្រ័យ = (ម.ថ. អ័ត-ធ្យាស្រៃ) ន. សភាវៈ ដែលដេកអាស្រ័យនៅក្នុងចិត្ត គឺបំណង, បំណង់ចិត្ត, បំណុបចិត្ត ។

១. អក្ខរាវិរុទ្ធ

## ព្រហ្ម-ព្រំ

ព្រហ្ម= (ម.ថ.ព្រំ) ន. ទេវតាដែលកើតនៅព្រហ្មលោក (ព្រះព្រហ្ម) ។

ព្រំ= កិ. ប្រក់ផ្គួតដំបូល (ព្រំដំបូលផ្ទះ) ។

ព្រំ= ន. កន្ទួនដែលព្រំហើយ (ក្មៀនលេចត្រង់ព្រំ) ។

ព្រំ= ន. បារីកដី, ទីបំផុតដែលប្រទល់គ្នា (ព្រំដែនព្រំចំការ, ព្រំប្រទល់) ។

ព្រំ= ន. ឈ្មោះកម្រាលពិសេសមួយយ៉ាង សម្រាប់ក្រាលដាលំអ (ក្រាលព្រំសម្រាប់ទទួលព្រះសង្ឃ) ។

ចំពោះអក្សរ ភ្ញ ត្រង់ពាក្យភ្ញុំ គ្មានប្រើឡើយ មានប្រើតែពាក្យ ភ្ញុំផាង, ភ្ញុំភ្លៀង ពីរម៉ាត់ប៉ុណ្ណោះ ។

ភ្ញុំ = សរសេរជាភ+ញ+ុំ (ភ្ញុំ) ។

ភ្នំ = សរសេរជាភ+ន+ំ (ភ្នំ) ។

ចំពោះអក្សរ មុ ជាពាក្យមួយព្យាង្គគ្មានប្រើពាក្យ មុំ យ៉ាងនេះឡើយ, មានប្រើតែពាក្យ មុំ ម្ក មុម (ជ្រុងជាយ) នេះប៉ុណ្ណោះ ។

# ១៨. អាកប្បកិរិយា

អាកប្បកិរិយារបស់មនុស្សមែនប្លែក ៗ គ្នាពីរូបមួយទៅរូបមួយ ។ អ្នកធ្លាប់នៅក្រោមបង្គាប់គេ មានឫកពាសំដីសំដៅព្រមទាំងសកិរិយា ប្លែកពីអ្នកជានាយលើគេ ។ អ្នកមានប្លែកពីអ្នកក្រ, អ្នកក្លាហានប្លែកពីអ្នកខ្លាចជាដើម ។ អាកប្បកិរិយានេះជាគ្រឿងសម្តែងនូវបុគ្គលិកលក្ខណៈរបស់យើង ។ ក្នុងការទាក់ទងគ្នាជមួតា អ្នកដទៃតែងប្រព្រឹត្តខ្លួនឲ្យស្របតាមអាកប្បកិរិយារបស់យើង សមដូចពុទ្ធភាសិតមួយបទថា «អ្នកបូជាតែងបានបូជាតប» ចំណែកហេតុការណ៍ផ្សេងៗក៏ទទួលនូវអានុភាពនៃអាកប្បកិរិយារបស់យើងដែរ ព្រោះលោកខាងក្រៅពុំមែនជាអាក្រក់ឬជាល្អបាន ព្រោះការទាក់ទងរវាងយើងនឹងលោកនោះប៉ុណ្ណោះ ក្នុងរឿងនេះ លោកគ្រូពេទ្យវិចទ័រប៊ូសេត៍ បានសរសើរថា: «លោកនេះជាកញ្ចក់ដែលយើងតែងឆ្លុះមុខរបស់យើង បើយើងញញឹម លោកក៏ញញឹម

ដាក់ បើយើងបង្ហាញមុខមិនស្រស់ លោកក៏ធ្វើមុខជូរតបមកវិញ„ ដូច្នេះយើងប្រើអាកប្បកិរិយាបែបណា អ្នកដទៃនឹងហេតុការណ៍ក៏ប្រព្រឹត្តស្របតាមអាកប្បកិរិយាបែបនោះ ។

### គ. ពាក្យពន្យល់

អាកប្បកិរិយា= (ម.ថ. អាក័ប-ប៉ៈកិរិយ៉ា) ន. អាការនៃកាយ, ដំណើរឬលំនាំនៃកាយឬនៃឫកពា ។

ឫកពា= ន. មារយាទ, កិរិយា, អាការកិរិយា, បែបបទ, សណ្ដាប់ធ្នាប់ (របស់រូបកាយ) ។

កិរិយា= (ម.ថ. កិរ៉ិយ៉ា) ន. អាការកំរើក, ការផ្លាស់ប្រែលំ-នាំ មានងាកបែរជាដើម, លំនាំឫកពា ។

បុគ្គលិកលក្ខណៈ=(ម.ថ. ប៊ុក-គៈលិកៈ ល័ក-ខៈណៈ) ន. លក្ខណៈសម្រាប់បុគ្គលម្នាក់ៗ ។

ពុទ្ធភាសិត= (ម.ថ. ពុត-ធៈ-) ន. ពាក្យប្រៀនប្រដៅរបស់

ព្រះពុទ្ធ (Proverbe du Bouddha) ។

បូជា= ន. ការថ្វាយឬជូនវត្ថុអ្វីៗ ចំពោះបូជនីយបុគ្គល, ការ-

ប្រព្រឹត្តតាមឱវាទរបស់បុគ្គលដែលគួរគោរព ។

លោក= ន. ទីឋានដែលសត្វអាស្រ័យនៅ ។

១. អក្ខរាវិរុទ្ធ

ចំពោះអក្សរ យំ មានប្រើតែពាក្យ យំ (កន្ទ្រយំ)

មួយម៉ាត់នេះប៉ុណ្ណោះ ។

រុំ–រុំ

រុំ= កិ. ក្រសោបព័ទ្ធជិតជុំវិញ (រុំដំបៅ, ផ្សែងរុំ

ផញ្ញាំង) ។

រុំ= កិ. ទម្លាក់ប៉ុនខ្លួន, បង្ហាប់កំសួលផែ្សង, ធ្វើ

(វៀជាកេតឬសដូងវិល) ។

ចំពោះពាក្យពីរព្យាង្គ, ឬច្រើនព្យាង្គ គេប្រើតែពាក្យ រុំ នេះ

ដោយភាគច្រើន,

ដូចជា :

រំកាប់, រំកិល, រំខាន, រំងាស់, រំដួល, រំពាត់,

រំភើប, រំលត់ ។ល។

ចំណែករុំ មានប្រើតែមួយម៉ាត់ប៉ុណ្ណោះគឺ :

រុំកោះ = ដែលដំពាក់ធ្លាក់ (ដំពាក់បំណុលគេរុំកោះ, ក្ដួលរុំកោះ) ។

ចំពោះអក្សរ លំ ទាំងពាក្យមួយព្យាង្គ, ទាំងពាក្យពីរព្យាង្គ ទីងច្រើនព្យាង្គ ប្រើសុទ្ធតែ លំ (ល+ំ) នេះប៉ុណ្ណោះ,

ដូចជា :

លំៗ, លំបង់, លំដាប់, លំនាំ, លំអក់ពំណោ, លំអៀង ។ល។

## ១៩. សេចក្ដីខ្លាច

សេចក្ដីខ្លាច សេចក្ដីញញើតញញើម នាំឲ្យតក់ស្លុត នាំឲ្យខូចកម្លាំងចិត្ត ធ្វើអ្វីមិនបានសម្រេចដូចបំណង ធ្វើយូរជាងគេផង ហើយមិនបានល្អផង មកពីមិនទុកចិត្តខ្លួនឯង រអែងក្រែងខុស នាំឲ្យគេចំអកឲ្យ ជួនកាលខ្លាចកប៉ាល់ ខ្លាចរន្ទះ ខ្លាចខ្យល់ព្យុះជាដើម រវល់តែព្រួយបារម្ភជានិច្ច រកសុខពុំឃើញ ៗ ទាំងអស់នេះ ដោយភាគច្រើន មកពីការអប់រំពីតូចមក ៗ ពីកាលនៅក្មេង, ចាស់ៗ ច្រើនបន្លាចឲ្យខ្លាចទីទុយ ខ្លាចឆ្មាអោង ឲ្យខ្លាចនេះខ្លាចនោះជាដើម ត្រង់នេះគួរមាតាបិតាទាំងឡាយចៀសវាងកុំបន្លាចកូនតូចៗ ឲ្យសោះ ខ្វះអ្វីដីដទៃសម្រាប់លួងវាឲ្យបាត់កិកកុកប្លុំយនោះ ៗ ចំណែកអ្នកខ្លាចខ្លាចមកហើយ ត្រូវពិចារណាឲ្យឃើញថា យើងជាមនុស្សមិនត្រូវខ្លាចខុសទំនងទេ ខ្លាចចំពោះវត្ថុណា ពិចារណាវត្ថុនោះ ឲ្យច្បាស់លាស់ ឲ្យដឹងថាជាវត្ថុមិនគួរខ្លាចទេ ៗ

ឯការខ្លាចគេសើចវិញនោះ យើងត្រូវចាំថា ការធ្វើអ្វីមែនមានខុសជាដរាប ការខុសនេះជាគ្រូនាំឲ្យយើងធ្វើត្រូវ ។

## ៣. ពាក្យពន្យល់

សេចក្ដីខ្លាច = ន. ការមានចិត្តទន់ខ្សោយចំពោះអ្នកដទៃ ។

បំអក = កិ. ស្ដីឲ្យកឲ្យ ។

ផ្ទុះ = ន. ដំណើរបែកចេញនៃធាតុអគ្គិសនីឯអាកាស ។

ប្រាម្ភ = (ម. ថ. ប្រារ៉ម់) (ទីនេះជាកិ.) ថប់ ឬ ព្រួយ ។

បន្លាច = (ម.ថ. បន់ឡាច) កិ. ធ្វើឲ្យខ្លាច ។

ពិចារណា = កិ. ត្រិះរិះ, រំពឹង, គិតគ្នេរ ។

### ១. អក្ខរាវិរុទ្ធ

ប្រាម្ភ = (ម.ថ. ប្រារ៉ម់) សរសេរជា ប្រា + រ + ម + ្ភ (ជើងភ) ។

## ឆ្មា - ឆ្មារ

ឆ្មា= ន. បសុសត្វចតុប្បាទមួយយ៉ាង ជាសត្រូវនឹងកណ្ដុរ (គេសរសេរគ្មានរ ជើងឡើយ) ។

ឆ្មារ= គុ. តូចបំផុត, ដែលស្រួយហើយស្រួចក្រៀវ ឧទា. សរសៃអំបោះឆ្មារ, សំឡេងឆ្មារ (ឆ្មារ= គុ. នេះគប្បីសរសេរមានរ ខាងចុង) ។

## ខ្វាស-ខ្វះ

ខ្វាស ៗ= កិ.វិ. ដែលវារឬលូនខ្វៃ ៗ ឧទា. អណ្ដើកវារខ្វាសៗ (ខ្វាស= កិ.វិ. នេះគប្បីសរសេរជា: ខ + ្វ + ា + ស) ។

ខ្វះ= កិ. ឬ គុ. ដែលមិនគ្រប់តាមខ្នាតកម្រិត ឧទា. ខ្វះតែបីទៀតនឹងគ្រប់ជាម្ភៃ (ខ្វះ= កិ. ឬ គុ. នេះ គប្បីសរសេរជា: ខ + ្វ + ះ)

# លស់ លាស់-លោះ

លស់= កិ. ធ្វើឲ្យរលស់, ឧទា. ក្នុងចំនួន ៧ លស់ ៣ ចេញទៅសល់ ៤; លស់ចោលជូនអ្នកខ្លះ ៗ

លាស់= កិ. លូតបែកចេញសន្ទឹក, ឧទា. ស្លឹកឈើលាស់ ៗ

លោះ= កិ. ចេញថ្លៃយករបស់ដែលបញ្ចាំ ឬយកមនុស្សមកធ្វើជាទាស ឬទាសី, ឧទា. លោះរបស់បញ្ចាំ; លោះមនុស្សយកមកប្រើ, លោះខ្លួនឲ្យរួចជាអ្នកជា ៗ

លោះ= ន. ឈ្មោះឈើមួយយ៉ាង, ឧទា. ដើមលោះ ៗ

# ២០. សតិ

សតិគឺការរលឹកចាំបាននូវកិច្ចការ ដែលបានធ្វើហើយ ពាក្យដែលបានពោលហើយ វត្ថុដែលបានឃើញ បានឮហើយ ជាគុណធម៌សំខាន់មួយក្នុងការកសាងខ្លួនឲ្យបានល្អៗ ដោយអាស្រ័យសតិនេះហើយ ទើបយើងអាចយកខ្លួន ជាគតិរបស់ខ្លួនបាន គឺអាចពិចារណាខ្លួនឲ្យបានដឹងថា គេបានចំរើនដល់កំរិតណា នៅសៅហ្មងបែបណាខ្លះ ហើយខំប្រឹងកែប្រែឲ្យបានវិសេសឡើងៗ

ដើម្បីចំរើនសតិខាងទស្សនភាព ត្រូវយើងបង្ហាត់ខ្លួនយើងឲ្យចេះសំឡឹងមើលវត្ថុនានាឲ្យអស់ដើម មានសណ្ឋានទ្រង់ទ្រាយ ពណ៌ សម្បុរ ទំហំ ទម្ងន់ជាដើម កុំឲ្យក្អែករពេយ-មាយទៅគ្រប់វត្ថុដោយឥតយកចិត្តទុកដាក់ គឺសំឡឹងមើលដោយពិនិត្យពិច័យ កុំឲ្យគ្រាន់តែឃើញ ៗ

ចំណែកសតិខាងសុតភាព ក៏ត្រូវហាត់ស្តាប់ឲ្យចាំជាក់

កុំឲ្យគ្រាន់តែពូ ។ ការរៀនភាសាតាងប្រទេសតាមថាស ជាការហាត់សតិខាងសុតភាព យ៉ាងសំខាន់ ត្រូវប្រើការបង្គាប់ខ្លួនយើងផ្សំផងថា «ខ្ញុំហ្វឹកហ្វឺនសតិរបស់ខ្ញុំគ្រប់ពេល» ។

ដើម្បីជួយសតិរបស់យើងឲ្យប្រតិបត្តិការ ដោយខែងវ៉ែង យើងគោងធ្វើអ្វីដោយមូលអារម្មណ៍ បំពោះកិច្ចការនោះ កុំបណ្ដោយគំនិតឲ្យរាយមាយផ្ដេសផ្ដាស ។

## ភា. ពាក្យពន្យល់

សតិ = ន. ស្មារតី, ការនឹកឃើញ, ការប្រុងប្រយ័ត្នមិនឲ្យភ្លេច ។

គុណធម៌ = (ម. ព. ក្នុងអត្ថបទបង់បត់) ។

គតិ = ន. ដំណើរ, តម្រាប់, លំនាំ, បែបបទ ។

កិរ្តិ = ន. ការដែលបានក្រិតទុក, បញ្ញត្តិ ។

សៅហ្មង = គុ. អាប់អន់, មានមន្ទិល, ប្រឡាក់, មិន

បរិសុទ្ធ ។

វិសេស = គុ. ថ្លៃថ្លា, ប្រសើរ, ខ្ពង់ខ្ពស់ ។

ទស្សនភាព = (ម. ថ. ទ័ស-ស:ន:ភាប) ន. ភាព

នៃការឃើញ ។

វិតនានា = របស់ផ្សេង ៗ ។

សណ្ឋាន = ន. (ម.ថ. សន់ឋាន) ន. ទ្រង់ទ្រាយ, រូប

រាង, បែបភាព ។

រាយមាយ = គុ. រវើរវាយ, ដែលមានអារម្មណ៍សាត់

អណ្តែតពត់ពាយ, ដែលពុំប្រាកដ, ចាប់នេះចាប់នោះ

មិនខ្ជាប់ខ្ជួនណា ។

ពិនិត្យពិច័យ = កិ. ពិចារណា, សង្កេតមើលដោយល្អិត

ល្អន់ ។

សុតភាព = (ម. ថ. សុត:ភាប) ន. ភាពនៃការស្តាប់,

ការស្ដាប់ ។

តាងប្រទេស = ន. ប្រទេសដទៃ, បរទេស (étranger)

ខែងរ៉ែង = គុ. រឹងប៉ឹង, ម៉ត់ចត់ ។

អារម្មណ៍ = (ម.ថ. អា៉ម់) ន. គំនិត, គ្រឿងគោល
របស់ចិត្ត, គ្រឿងទាញយករបស់ចិត្ត ។

១. អត្ថាភិវុឌ្ឍ

ពាក្យពីរព្យាង្គខ្លះ អាចសរសេរបានពីរយ៉ាងឬបីយ៉ាងផង គឺសរសេរតម្រួតគ្នាក៏បាន រាយតួក៏បាន ។

ពាក្យទាំងនោះគឺ :

កំឡាំង = កម្លាំង = កំលាំង

កំសត់ = កម្សត់

កម្រ = កំរ

គម្រប = គំរប

គម្រប់ = គំរប់

ជម្ងឺ = ជំងឺ

ជម្បាញ = ជំបាញ

តម្រា = តំរា

របាស = របាស់

សម្រាន្ត = សំរាន្ត ។ល។

វៀរលែងតែពាក្យទាំងនេះគឺ :

សំខាន់, សំគាល់, សំបែ, សំដី, សំដៅ,

សំណា, សំណល់ ជាដើម ។

វណ្ណយុត្ត (:) នេះមិនដែលសរសេរពីក្រោយពាក្យ

ដែលមានស្រៈដទៃក្រៅពីស្រៈ អ ឡើយ

ដូចជា :

សតិ, មិនដែលសរសេរជា សតិៈ ឡើយ; តុ, មិន
ដែលសរសេរជា តុៈ ឡើយ ៗលៗ